**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ

កម្មសិក្សាពីថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៨

តាក់តែងឡើងដោយ
និស្សិតឈ្មោះ ក. **កែ ហួយ**

សាស្ត្រាចារ្យណែនាំ
លោក **ថោង ចន្ត្រា**

ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ
ជំនាន់ទី១១ (អាហារូបករណ៍)

ឆ្នាំចូលរៀន ២០១៤
ឆ្នាំសរសេររបាយការណ៍ ២០១៨

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **កែ ហួយ** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាន់ទី១១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៧-២០១៨ សូមគោរព និងសម្តែងនូវកត្តញ្ញូតាធម៌ដឹងគុណយ៉ាងខ្ពង់ខ្ពស់បំផុតចំពោះ ៖

❖ **លោកឪពុកអ្នកម្តាយ** ដែលលោកជាអ្នកមានគុណយ៉ាងធំធេង ដោយលោកទាំងពីរបានផ្តល់កំណើតដល់រូបខ្ញុំ ព្រមទាំងលះបង់ទាំងកម្លាំងកាយនិងចិត្ត ក្នុងការចិញ្ចឹមបីបាច់ អប់រំទូន្មានប្រៀនប្រដៅ ប្រកបដោយព្រហ្មវិហារធម៌ល្អប្រពៃ ។

❖ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យ អនុប្រធានការិយាល័យ ព្រមទាំងសាស្ត្រាចារ្យគ្រប់មុខវិជ្ជាទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានលះបង់កម្លាំងកាយនិងចិត្ត ក្នុងការបណ្តុះបណ្តាលយុវជនជំនាន់ក្រោយដែលជាទំពាំងស្នងឬស្សីឲ្យមានចំណេះដឹង ដើម្បីជាប្រយោជន៍ និងជាស្ពានឆ្ពោះទៅរកភាពជោគជ័យនាពេលបច្ចុប្បន្ននិងពេលអនាគត ។

❖ **លោកសាស្ត្រាចារ្យ ថោង ចន្ថា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំផ្តល់ជាមតិយោបល់និងគំនិតល្អៗ ព្រមទាំងជួយដឹកនាំកែសម្រួលក្នុងកិច្ចការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សារបស់នាងខ្ញុំតាំងពីដើមរៀងមករហូតទទួលបានជោគជ័យជាស្ថាពរ ។

❖ **ឯកឧត្តម ហ៊ី បាវី** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានអគ្គនាយកនៃកំពង់ផែស្វយ័តភ្នំពេញដែលបានអនុញ្ញាតឲ្យនាងខ្ញុំបានមកចុះកម្មសិក្សានៅកំពង់ផែស្វយ័តភ្នំពេញ។

❖ **លោក គង់ សុធា** ជាប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស និង **លោក ហ៊ឹ សុខ** ជាប្រធានការិយាល័យបុគ្គលិក/បណ្តុះបណ្តាល ដែលបានចំណាយពេលដ៏មានតម្លៃសម្រាប់ធ្វើការណែនាំដល់នាងខ្ញុំកំឡុងពេលចុះកម្មសិក្សា។

ដើម្បីជាកិច្ចតបស្នងនូវទឹកចិត្តដ៏សប្បុរសថ្លៃថ្លានេះ នាងខ្ញុំសូមបួងសួង និងជូនពរចំពោះអ្នកមានគុណទាំងពីរ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យ អនុប្រធានការិយាល័យ ព្រមទាំងសាស្ត្រាចារ្យគ្រប់មុខវិជ្ជាទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងបុគ្គលិកទាំងអស់នៃកំពង់ផែស្វយ័តភ្នំពេញ សូមទទួលបាននូវពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ក្រោយការសិក្សានូវជំនាញរដ្ឋបាលសាធារណៈរយៈពេល៤ឆ្នាំកន្លងមកនេះ នាងខ្ញុំសង្កេតឃើញថាវិស័យរដ្ឋបាល គឺជាវិស័យមួយដ៏សំខាន់នៅក្នុងចំណោមវិស័យផ្សេងៗ។ ដោយហេតុថាវិស័យនេះគឺជាគន្លងមួយក្នុងការគ្រប់គ្រងក្រសួង-ស្ថាប័ននានា ឲ្យមានការប្រព្រឹត្តទៅដោយរលូន។ ទន្ទឹមនឹងនេះ នាងខ្ញុំបានទទួលនូវចំណេះដឹង និងបទពិសោធន៍ល្អៗជាច្រើនពីសំណាក់លោកសាស្ត្រាចារ្យ និងលោកស្រីសាស្ត្រាចារ្យ។ ដោយរួមផ្សំ និងការខិតខំប្រឹងប្រែងពុះពារគ្រប់ឧបសគ្គកន្លងមក នាងខ្ញុំពិតជាមានមោទនភាព ដែលបានទទួលឱកាសក្នុងការសរសេររបាយការណ៍កម្មសិក្សានៅកំពង់ផែស្វយ័តភ្នំពេញស្តីអំពី "ការគ្រប់គ្រងរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ" ដើម្បីទុកជាស្នាដៃមួយក្នុងការសិក្សានៅថ្នាក់បរិញ្ញាបត្រនេះ។ ម្យ៉ាងវិញទៀតចំពោះការសរសេររបាយការណ៍កម្មសិក្សានេះ នាងខ្ញុំបានចុះកម្មសិក្សានៅកំពង់ផែស្វយ័តដោយផ្ទាល់ ហើយបានធ្វើការប្រមូលព័ត៌មាន និងឯកសារមួយចំនួនដើម្បីជាស្ពានក្នុងការតាក់តែងជាសៀវភៅនេះឡើង។

ចំពោះស្នាដៃមួយនេះ នាងខ្ញុំបានខិតខំប្រឹងប្រែងក្នុងការសិក្សាស្រាវជ្រាវប្រមូលព័ត៌មានដើម្បីយកមកសរសេរចងក្រងនិងពិនិត្យយ៉ាងផ្ចិតផ្ចង់ តែនាងខ្ញុំនៅតែជឿជាក់ថាការស្រាវជ្រាវនេះគង់មាននូវចំណុចចន្លោះប្រហោង និងពុំទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ។ អាស្រ័យហេតុនេះនាងខ្ញុំសូមអធ្យាស្រ័យនូវរាល់ចំណុចខ្វះខាត ការឆ្គាំឆ្គងនូវពាក្យពេចន៍ណាមួយ ព្រមទាំងអត្ថន័យខ្លឹមសារ និង កំហុសជាអក្ខរាវិរុទ្ធផងដែរ។

ជាទីបញ្ចប់នាងខ្ញុំ សូមថ្លែងអំណរគុណទុកជាមុនពីសំណាក់លោកសាស្ត្រាចារ្យ និងលោក-ស្រីសាស្ត្រាចារ្យ និង ប្រិយមិត្តនិស្សិតព្រមទាំងមិត្តអ្នកអានទាំងអស់ និងសូមជូនពរដល់ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យ-លោកស្រីសាស្ត្រាចារ្យ មិត្តនិស្សិតទាំងអស់សូមឲ្យជួបប្រទះតែសំណាងល្អ សុខភាពល្អ ទទួលបានជោគជ័យគ្រប់ភារកិច្ច សេចក្តីសុខនិងសុភមង្គលជារៀងដរាបដើម្បីរួមចំណែកគ្នាក្នុងការអភិវឌ្ឍនាវាកម្ពុជាឆ្ពោះទៅរកភាពរីកចម្រើនជាលំដាប់ ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ទស្សនៈទូទៅនៃសហគ្រាសសាធារណៈ**

**១.១. សញ្ញាណទូទៅនៃសហគ្រាសសាធារណៈ** ........ ៥

**១.១.១. អត្ថន័យនៃសហគ្រាសសាធារណៈ** ........ ៥

**១.១.២. សិទ្ធិ និងភាតព្វកិច្ចសហគ្រាសសាធារណៈ** ........ ៦

១.១.២.១. ភារកិច្ច និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាភិបាល ........ ៦

១.១.២.២. កាតព្វកិច្ចរបស់សហគ្រាសសាធារណៈ ........ ៨

១.១.២.៣. ការត្រួតពិនិត្យសហគ្រាសសាធារណៈ ........ ៨

**១.២. ទំនាក់ទំនងរវាងសហគ្រាសសាធារណៈ និងរដ្ឋ** ........ ១០

**១.២.១. ការត្រួតពិនិត្យរបស់រដ្ឋ** ........ ១០

**ជំពូកទី២**

**ដំណើរការគ្រប់គ្រងរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ**

**២.១.ស្ថានភាពទូទៅនៃកំពង់ផែស្វយ័តភ្នំពេញ** ........ ១១

២.១.១. ប្រវត្តិកំពង់ផែស្វយ័តភ្នំពេញ ........ ១១

២.១.២. មណ្ឌលអាជីវកម្មផែភ្នំពេញ ........ ១៣

២.១.៣. តួនាទីរបស់កំពង់ផែស្វយ័តភ្នំពេញ ........ ១៤

**២.២. ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ** ........ ១៥

**២.២.១. រចនាសម្ព័ន្ធនៃការគ្រប់គ្រង** ........ ១៥

២.២.១.១. សមាសភាពក្រុមប្រឹក្សាភិបាល ........ ១៥

២.២.១.២. គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល ........ ១៧

២.២.១.៣. អគ្គនាយក ........ ១៨

២.២.១.៤. អគ្គនាយករង ........ ១៩

២.២.១.៥. ប្រធាននាយកដ្ឋាន ........ ១៩

**២.២.២. ហិរញ្ញវត្ថុរបស់កំពង់ផែស្វយ័តភ្នំពេញ** ...... ៣០
២.២.២.១. ចំណូល ...... ៣០
២.២.២.២. ចំណាយ ...... ៣០
២.២.២.៣. ប្រាក់ឧបត្ថម្ភដល់សមាជិកក្រុមប្រឹក្សា និងបុគ្គលិក ...... ៣០
**២.៣. ផែនការអនាគតសម្រាប់ឆ្នាំ ២០១៨** ...... ៣១
**២.៤. ទិសដៅការងារឆ្នាំ ២០១៨** ...... ៣៣

## ជំពូកទី៣
## ការអនុវត្តកិច្ចការរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ

**៣.១. កិច្ចប្រជុំ** ...... ៣៥
៣.១.១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ...... ៣៥
៣.១.២. កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក ...... ៣៦
**៣.២. លិខិតរដ្ឋបាលរបស់ ក.ស.ភ** ...... ៣៧
**៣.៣. ចំណុចខ្លាំង និងចំណុចខ្សោយ** ...... ៣៨
៣.៣.១. ចំណុចខ្លាំង ...... ៣៨
៣.៣.២. ចំណុចខ្សោយ ...... ៣៨
**សេចក្តីសន្និដ្ឋាន** ...... ៣៩
**អនុសាសន៍** ...... ៤០
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅលើពិភពលោកយើងនេះ រាល់បណ្តាប្រទេសណាដែលមានសេដ្ឋកិច្ចរីកចម្រើននិងលូតលាស់ខ្ពស់ទៅមុខ ប្រទេសទាំងនោះតែងតែទទួលបាននូវការទទួលស្គាល់ប្រកបដោយកិត្តិយសពីសំណាក់សហគមអន្តរជាតិ។ ដោយឡែកប្រទេសខ្សត់ខ្សោយវិញ គឺស្ទើរតែត្រូវបានគេបំភ្លេចចោលពីឆាកអន្តរជាតិផងក៏មានដែរ។ នេះមិនត្រឹមតែជាមហិច្ឆិតារបស់មេដឹកនាំប្រទេសនីមួយៗទេ សូម្បីតែប្រជាជនទូទៅ ក៏ប្រាថ្នាចង់ឲ្យប្រទេសជាតិខ្លួនក្លាយទៅជាប្រទេសមួយដែរត្រូវបានពិភពលោកទាំងមូលទទួលស្គាល់។ យ៉ាងណាមិញ ប្រទេសកម្ពុជាយើងក៏មានក្តីប្រាថ្នាចង់ឲ្យប្រទេសរបស់ខ្លួនមានការរីកចម្រើន និងសម្បូរសប្បាយដូចបណ្តាប្រទេសជឿនលឿនដែរ។ ប៉ុន្តែដោយកម្ពុជាធ្លាប់បានធ្លាក់ចូលទៅក្នុងជម្លោះ និងសង្គ្រាមស៊ីវិលអស់រយៈពេលជាច្រើនឆ្នាំ ទើបធ្វើឲ្យកម្ពុជាជួបប្រទះនូវឧបសគ្គផ្សេងៗជាច្រើន ដែលមានភាពរាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ បើទោះបីជាយ៉ាងនេះក៏ដោយ បន្ទាប់ពីមានការខិតខំប្រឹងប្រែងស្តាបនានិងស្តារឡើងវិញអស់រយៈពេលជាង ៣០ ឆ្នាំកន្លងមកនេះ កម្ពុជាហាក់ដូចជាមានលំនឹង ដើម្បីចាប់ផ្តើមដំណាក់កាលបន្តបន្ទាប់ក្នុងការអភិវឌ្ឍ។ ការវិវត្តន៍ខ្លួនឲ្យក្លាយជាប្រទេសអភិវឌ្ឍទៅបាននោះវាអាស្រ័យទៅលើកត្តាជាច្រើនរួមផ្សំគ្នា ជាពិសេសនោះគឺវិស័យសេដ្ឋកិច្ច និងរដ្ឋបាល។

ដោយឡែកកំពង់ផែស្វយ័តភ្នំពេញ ឬហៅកាត់ថា ក.ស.ភ ជាសហគ្រាសសាធារណៈមួយហើយក៏ជាទីកន្លែងសម្រាប់នាំចេញ-ចូល លើកដាក់ ផ្ទេរ-ផ្ទុក ដឹកជញ្ជូននូវទំនិញក្នុងប្រទេសកម្ពុជាដែលតម្រូវឲ្យមានការគ្រប់គ្រងមួយប្រកបដោយលក្ខណៈល្អប្រសើរ ដើម្បីសម្រួលនូវរាល់តម្រូវការរបស់អតិថិជន ជាពិសេសគឺផ្នែកសេវាកម្ម។ ដូច្នេះហើយដើម្បីឲ្យ ក.ស.ភ មានដំណើរការដែលមានលក្ខណៈល្អប្រសើរ និងមានការអភិវឌ្ឍដោយទទួលបានការគាំទ្រខ្ពស់នោះ ក.ស.ភ ចាំបាច់ត្រូវតែធ្វើការឲ្យបានម៉ត់ចត់និងខ្ជាប់ខ្ជួន ដែលទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាលដើម្បីបង្កើននូវសក្តានុពលរបស់ខ្លួន និងធ្វើឲ្យស្ថាប័នកាន់តែមានការរីកចម្រើន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការគ្រប់គ្រងរដ្ឋបាល គឺជាផ្នែកមួយដ៏សំខាន់ក្នុងដំណើរការប្រព្រឹត្តទៅនៃស្ថាប័ននីមួយៗហើយជាកត្តាជម្រុញមួយដែលមានអត្ថប្រយោជន៍បំផុត ដើម្បីឲ្យដំណើរការនៃស្ថាប័ននោះប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ។ ដូច្នេះ ដើម្បីយល់ដឹងឲ្យកាន់តែស៊ីជម្រៅអំពីទ្រឹស្តី និងការអនុវត្តជាក់ស្តែងរបស់ ក.ស.ភ ខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់បន្ថែមទៅលើការគ្រប់គ្រងរដ្ឋបាលរបស់ ក.ស.ភ ដោយផ្ទាល់។

- តើ ក.ស.ភ គឺជាស្ថាប័នអ្វី?

- តើតួនាទី ភារកិច្ច និងទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល អគ្គនាយក អគ្គនាយករង និងប្រធាននាយកដ្ឋាន រួមមានអ្វីខ្លះ?

- តើចំណុចខ្លាំង និងចំណុចខ្សោយរបស់ ក.ស.ភ មានអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺចង់សិក្សាស្វែងយល់អំពីរបៀបនៃការគ្រប់គ្រងរដ្ឋបាលរបស់កំពង់ផែស្វយ័តភ្នំពេញ(ក.ស.ភ) ដែរទាក់ទងទៅនឹងបញ្ហាមួយចំនួនដូចជាៈ

- ទ្រឹស្តីទូទៅនៃសហគ្រាសសាធារណៈ
- ដំណើរការគ្រប់គ្រងរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ
- ការអនុវត្តកិច្ចការរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការស្រាវជ្រាវ និងចងក្រងជារបាយការណ៍នេះ គឺបានផ្តល់នូវចំណេះដឹងបទពិសោធន៍ និងអត្ថប្រយោជន៍ជាច្រើនដល់និស្សិតដែលជាអ្នកធ្វើការសិក្សាស្រាវជ្រាវដោយផ្ទាល់តាមស្ថាប័ន ក៏ដូចជាអ្នកស្រាវជ្រាវដទៃទៀតផងដែរ។ បន្ថែមពីនេះទៅទៀតការសិក្សាស្រាវជ្រាវបានផ្តល់ឱកាសក្នុងការសិក្សាស្វែងយល់ពី ការអនុវត្តន៍ជាក់ស្តែងរបស់អង្គភាពផ្ទាល់ ស្គាល់ពីភាពលំបាក និងងាយស្រួលក្នុងដំណើរការការងារ។ ម្យ៉ាងវិញការសិក្សាស្រាវជ្រាវក៏បានផ្តល់នូវចំណេះដឹងមួយចំនួនដូចជា ៖

- ភាពខុសគ្នារវាងទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែង
- យល់ដឹងពីការអនុវត្តន៍ការងារ និងឥរិយាបថការងារនៅក្នុងអង្គភាព
- យល់ដឹងពីបរិបទការងារនៃការគ្រប់គ្រងរដ្ឋបាលនៅក្នុងអង្គភាព
- ផ្តល់ជារបាយការណ៍គំរូសម្រាប់និស្សិតជំនាន់ក្រោយដើម្បីស្វែងយល់ និងស្រាវជ្រាវបន្ត

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សម្រាប់របាយការណ៍កម្មសិក្សានេះ យើងមិនបានធ្វើការសិក្សាទៅលើការគ្រប់គ្រងរដ្ឋបាលរបស់ ក.ស.ភ គ្រប់សាខាទាំងអស់នោះទេ គឺធ្វើការសិក្សាស្រាវជ្រាវតែលើការគ្រប់គ្រងរដ្ឋបាលរបស់ ក.ស.ភ ដែលមានទីតាំងស្ថិតនៅអគារលេខ៦៤៩ តិរៈវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចកខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ជាមួយគ្នានេះដែរការសិក្សានេះគឺគិតពីឆ្នាំ២០១៥ ដល់ ២០១៨។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការប្រមូលទិន្នន័យ ក៏ដូចជាព័ត៌មានផ្សេងៗសំរាប់ធ្វើការស្រាវជ្រាវនិងយកមកចងក្រងជារបាយការណ៍នេះ នាងខ្ញុំប្រើវិធីពីរយ៉ាងដើម្បីយកមកប្រើក្នុងការសរសេររបាយការណ៍កម្មសិក្សាមានដូចខាងក្រោម៖

➢ **ទិន្នន័យដំបូង** (Primary Data)

ទាក់ទិនទៅនឹងការប្រមូលទិន្នន័យដំបូង នាងខ្ញុំបានខិតខំធ្វើការប្រមូលទិន្នន័យនិងព័ត៌មានតាមរយៈ៖

- ការសាកសួរ និង សម្ភាសន៍ផ្ទាល់ជាមួយនិងបុគ្គលិកដែលបានបម្រើការងារនៅក្នុង ក.ស.ភ
- ការអង្កេតទូទៅលើដំណើរការនៃការងាររបស់ ក.ស.ភ

➢ **ទិន្នន័យបន្ទាប់បន្សំ**(Secondary Data)

ចំពោះការប្រមូលទិន្នន័យទីពីរនេះ នាងខ្ញុំធ្វើការប្រមូលព័ត៌មាន និងទិន្នន័យតាមរយៈ៖

- ការណែនាំពីសំណាក់សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឯកសារនិងទិន្នន័យមួយចំនួន ដែលបានផ្តល់ដោយ ក.ស.ភ
- សិក្សាឯកសារបន្ថែមតាមរយៈគេហទំព័រអ៊ិនធឺណេតរបស់សហគ្រាស

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះរបាយការណ៍កម្មសិក្សានេះ នាងខ្ញុំបានបែងចែកដូចខាងក្រោម៖

- **សេចក្តីផ្តើម៖** បង្ហាញអំពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណង សារសំខាន់ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការសរសេរសារណា ។

- **ជំពូកទី១៖** រំលឹកទ្រឹស្តី ដែលសិក្សាទៅលើសញ្ញាណទូទៅនៃសហគ្រាសសាធារណៈរួមមានអត្ថន័យនៃសហគ្រាសសាធារណៈ សិទ្ធិនិងកាតព្វកិច្ចសហគ្រាសសាធារណៈ និងទំនាក់ទំនងរវាងសហគ្រាសសាធារណៈ និងរដ្ឋ។

- **ជំពូកទី២៖** ដំណើរការគ្រប់គ្រងរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ ដែលសិក្សាពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលកំពង់ផែ អំពីតួនាទី ភារកិច្ច និងទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន រួមទាំងផែនការអនាគត និងទិសដៅការងារសម្រាប់ឆ្នាំ ២០១៨។

- **ជំពូកទី៣៖** ការអនុវត្តកិច្ចការរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ ក្នុងនោះរួមមាន កិច្ចប្រជុំក្រុម-ប្រឹក្សាភិបាល កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លិខិតរដ្ឋបាល ចំណុចខ្លាំងនិងចំណុចខ្សោយ។

- **សេចក្តីសន្និដ្ឋាន**
- **អនុសាសន៍**
- **គន្ថនិទ្ទេស**
- **ឧបសម្ព័ន្ធ**

# ជំពូកទី១
# ទស្សនៈទូទៅនៃ
# សហគ្រាសសាធារណៈ

# ជំពូកទី១

# ទស្សនៈទូទៅនៃសហគ្រាសសាធារណៈ

## ១.១. សញ្ញាណទូទៅនៃសហគ្រាសសាធារណៈ

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ ឬ ក្រុមហ៊ុន) គឺជាសហគ្រាសសាធារណៈដែលមានទម្រង់ជាក្រុមហ៊ុនរដ្ឋ ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ ៥១ អនក្រ.បក នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨។ ក.ស.ភ គឺជានីតិបុគ្គលសាធារណៈមានស្វ័យភាពផ្នែកបច្ចេកទេស ផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ។ ដោយឡែកនីតិបុគ្គលសាធារណៈមានពីរប្រភេទ គឺនីតិបុគ្គលសាធារណៈដែនដី (personnes morales publiques territoriales) និងនីតិបុគ្គលសាធារណៈបច្ចេកទេស (personnes morales publiques techniques)។ **នីតិបុគ្គលសាធារណៈបច្ចេកទេស** គឺជានីតិបុគ្គលសាធារណៈដែលត្រូវបានបង្កើតឡើងដើម្បីបំពេញការត្រូវការ ជាផលប្រយោជន៍សាធារណៈណាមួយច្បាស់ដោយឡែក ដូចជាដើម្បីគ្រប់គ្រងមន្ទីរពេទ្យ សាកលវិទ្យាល័យ អគ្គិសនី ឬការកំចាត់មីនជាដើម។ ដែលច្រើនជារឿងបច្ចេកទេស។ នីតិបុគ្គលសាធារណៈបច្ចេកទេស ត្រូវស្ថិតនៅក្រោមអាណាព្យាបាលរបស់នីតិបុគ្គលសាធារណៈដែនដី ដែលបានបង្កើតខ្លួនមក[1]។

### ១.១.១. អត្ថន័យនៃសហគ្រាសសាធារណៈ

សហគ្រាសសាធារណៈ គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ។ សហគ្រាសសាធារណៈមានបេសកកម្មបង្កលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើនអាជីព។ សហគ្រាសសាធារណៈ គឺជានីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុ ដោយក្រុមប្រឹក្សាភិបាលសហគ្រាសសាធារណៈ ដែលគេហៅកាត់ថាក្រុមប្រឹក្សាភិបាល ជាអង្គការដឹកនាំខ្ពស់បំផុតនៅក្នុងសហគ្រាសសាធារណៈ ហើយបំពេញមុខងារប្រកបដោយស្វ័យភាពបរិបូរណ៍ ហើយចំនួនសមាជិកនៃក្រុមប្រឹក្សាភិបាល មិនលើសពី ០៧ នាក់ឡើយ។ មួយវិញទៀតការគ្រប់គ្រងលើគ្រប់ផ្នែករបស់សហគ្រាសសាធារណៈ ត្រូវអនុលោមតាមគោលការណ៍និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយសហគ្រាសសាធារណៈត្រូវស្ថិតនៅក្រោមរបបនៃនីតិរូម ចំពោះពន្ធ និងអាករ។ សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួង ឬអាជ្ញាធរសាធារណៈណាមួយ អាស្រ័យលើសកម្មភាពរបស់សហគ្រាសនោះ។ សហគ្រាសសាធារណៈត្រូវស្ថិតនៅក្រោម ៖

- ការត្រួតពិនិត្យរបស់រដ្ឋ ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាស

[1] សៀវភៅស្តីពី"នីតិវិធីរដ្ឋបាលទូទៅ"រៀបរៀងដោយសាស្ត្រាចារ្យបណ្ឌិត សាយ បូរី,បោះពុម្ពលើកទី៣(២០០៦),ទំព័រ៣៣

សាធារណៈក្នុងផ្នែកទី៣ ជំពូកទី២

- ការត្រួតពិនិត្យហិរញ្ញវត្ថុ និងអធិការកិច្ចរបស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ

ចំណែកឯបុគ្គលិកដែលធ្វើការក្នុងសហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែកដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

➢ **ប្រភេទនៃសហគ្រាស**

សហគ្រាសសាធារណៈមានទម្រង់ជា ៖

**- គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច** គឺជានីតិបុគ្គលនៃនីតិសាធារណៈដែលមានស្វ័យភាពហិរញ្ញវត្ថុ។ គ្រឹះស្ថាននេះផលិតឥវ៉ាន់ ឬធ្វើសេវាសម្រាប់ទីផ្សារ។ គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យតាមការស្នើរមគ្នារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាលឬអាជ្ញាធរអាណាព្យាបាល។ អនុក្រឹត្យនេះកំណត់ជាអាទិ៍អំពីភារកិច្ច ដើមទុន ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល សមាសភាពក្រុមប្រឹក្សាភិបាល ការរៀបចំរដ្ឋបាលនិងហិរញ្ញវត្ថុ វិធាននៃការប្រព្រឹត្តទៅនៃគ្រឹះស្ថាន។

**- ក្រុមហ៊ុនរដ្ឋ** គឺជាក្រុមហ៊ុនដែលមានដើមទុនទាំងអស់ជារបស់រដ្ឋ។ ក្រុមហ៊ុនរដ្ឋត្រូវបានបង្កើតឡើងដោយអនុក្រឹត្យតាមការស្នើរមគ្នារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល។ អនុក្រឹត្យនេះកំណត់ជាអាទិ៍អំពី កម្មវត្ថុរបស់ក្រុមហ៊ុន ទម្រង់គតិយុត្ត ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល របបត្រួតពិនិត្យដែលត្រូវអនុវត្ត សមាសភាពរបស់ក្រុមប្រឹក្សាភិបាល។

**- ក្រុមហ៊ុនចម្រុះ** គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើង តាមគោលការណ៍និងតាមបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្មហើយដែលដើមទុន ត្រូវបានកាន់កាប់រួមគ្នាដោយនីតិបុគ្គល ឬរូបវន្តបុគ្គលឯកជន និងនីតិបុគ្គលរដ្ឋ។ កាលណាភាគកម្មសាធារណៈលើសពី ៥១ ភាគរយនៃដើមទុន ឬសិទ្ធិបោះឆ្នោត ក្រុមហ៊ុនចម្រុះត្រូវបានចាត់ទុកជាសហគ្រាសសាធារណៈ។

### ១.១.២. សិទ្ធិ និងភារកិច្ចសហគ្រាសសាធារណៈ

#### ១.១.២.១. ភារកិច្ច និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាភិបាល

ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ត្រូវមានអាសនៈមួយកន្លែងសម្រាប់តំណាងនិយោជិតនៃសហគ្រាសសាធារណៈដែលត្រូវបានបោះឆ្នោតជ្រើសតាំងចេញពីនិយោជិត និងដោយនិយោជិតរបស់សហគ្រាស។ ក្រុមប្រឹក្សាភិបាលអាចផ្ទេរឲ្យប្រធានអគ្គនាយក ឬអគ្គនាយកនូវអំណាចចាំបាច់សម្រាប់ដំណើរការសហគ្រាសប្រចាំថ្ងៃ តែការផ្ទេរអំណាចនេះមិនមែនការផ្ទេរការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលឡើយ។ មុខងារនៃប្រធានអគ្គនាយក ឬអគ្គនាយក ឬ

សមាជិកក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ មានវិសមិតភាពជាមួយមុខងារនៃសមាជិករដ្ឋសភា ឬសមាជិករាជរដ្ឋាភិបាល។

ក្រុមប្រឹក្សាភិបាលមានតួនាទី កំណត់ទិសដៅ និងត្រួតពិនិត្យការគ្រប់គ្រងសហគ្រាស ព្រមទាំងធានាសនិទានភាព និងប្រសិទ្ធភាពនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់សហគ្រាសហើយដើម្បីបំពេញមុខងារនេះក្រុមប្រឹក្សាភិបាលមានភារកិច្ចជាអាទិ៍ ៖

- សម្រេចគម្រោងអភិវឌ្ឍសហគ្រាស
- វាយតម្លៃក្នុងចន្លោះពេលមួយទៀងទាត់ នូវលទ្ធផលសម្រេចបាននិងលើកវិធានការកែតម្រូវសម្រាប់អនុវត្ត
- សម្រេចគម្រោងថវិកាសំរាប់ការប្រព្រឹត្តទៅ និងការវិនិយោគ ព្រមទាំងសេមាហិរញ្ញប្បទាន
- អនុម័តតុល្យការនិងគណនីគ្រប់គ្រង
- កំណត់រចនាសម្ព័ន្ធរបស់សហគ្រាស លក្ខន្តិកៈបុគ្គលិក និងរបៀបបៀរវត្ស
- អនុម័តការដេញថ្លៃសាធារណៈ។

ក្រុមប្រឹក្សាត្រូវប្រជុំយ៉ាងតិចមួយដងក្នុងរៀងរាល់ ០៣ខែ ដើម្បីពិភាក្សានិងសម្រេចនូវបញ្ហាដែលបានចុះក្នុងរបៀបវារៈ។ របៀបវារៈនេះនឹងត្រូវបានជូនដំណឹងជាមុនយ៉ាងតិច ១០ ថ្ងៃដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលដោយក្រុមប្រឹក្សាភិបាល ត្រូវចាត់ចែងធ្វើកំណត់ហេតុនានាឲ្យ ហើយនៅក្នុងរយៈពេល ១០(ដប់)ថ្ងៃ បន្ទាប់ពីការប្រជុំ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសហគ្រាសសាធារណៈណាមួយក្រុមប្រឹក្សាភិបាលអាចចាត់ទុកជាបានការ លុះត្រាតែសមាជិកភាគច្រើនចូលរួម ហើយក្រុមប្រឹក្សាភិបាលត្រូវសម្រេចដោយសម្លេងភាគច្រើននៃសមាជិកដែលមានវត្តមាន[2]។ ក្នុងករណីមានសម្លេងស្មើគ្នា នោះសម្លេងរបស់ប្រធានក្រុមប្រឹក្សាមានឧត្តមានុភាព។ ក្រុមប្រឹក្សាភិបាលត្រូវសម្រេចយ៉ាងយូរបំផុតនៅថ្ងៃទី៣០ ខែកញ្ញា រៀងរាល់ឆ្នាំនូវគម្រោងថវិកាសម្រាប់ការប្រព្រឹត្តទៅ និងការវិនិយោគ ព្រមទាំងសេមាហិរញ្ញប្បទាន។ ឯកសារទាំងនេះ ត្រូវមានការទទួលយល់ព្រមពីក្រសួងអាណាព្យាបាល ឬអាជ្ញាធរព្យាបាល បន្ទាប់ពីការផ្តល់យោបល់ឯកភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងរយៈពេលអតិបរមា ២ខែ គិតចាប់ពីថ្ងៃដែលឯកសារមកដល់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរព្យាបាល ហើយក្រុមប្រឹក្សាភិបាលត្រូវសម្រេចលើរបាយការណ៍ស្តីពីសកម្មភាពប្រចាំឆ្នាំ តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងឯកសារឧបសម្ព័ន្ធនានាយ៉ាងយូរបំផុត ៣ ខែក្រោយពេលបិទបញ្ជី។

---

[2] ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦,មាត្រា៩-មាត្រា១៣

**១.១.២.២. ភារកិច្ចរបស់សហគ្រាសសាធារណៈ**:

សហគ្រាសសាធារណៈត្រូវផ្តល់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរព្យាបាលនូវឯកសារដែលពាក់ព័ន្ធទៅនឹងៈ

- កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល
- ថវិកាសម្រាប់ការប្រព្រឹត្តទៅ និងការវិនិយោគ
- របាយការណ៍ស្តីពីសកម្មភាព តុល្យការនិងគណនីគ្រប់គ្រង ព្រមទាំងឯកសារឧបសម្ព័ន្ធ
- របាយការណ៍ស្តីពីការត្រួតពិនិត្យគណនីនានា។

ឯកសារនីមួយៗដែលបានធ្វើរួចរាល់តាមកាលកំណត់ ត្រូវបញ្ជូនទៅកន្លែងទទួលក្នុងរយៈពេលមិនលើសពី ១៥(ដប់ប្រាំ)ថ្ងៃ។ ក្រសួងអាណាព្យាបាល ឬអាជ្ញាធរព្យាបាលមានរយៈពេល ០១ខែ សម្រាប់ជំទាស់នៅក្នុងករណីចាំបាច់។ ក្រុមប្រឹក្សាភិបាលត្រូវបានផ្តល់ពត៌មានអំពីខ្លឹមសារនៃការជំទាស់ នៅពេលប្រជុំបន្ទាប់ដើម្បីចាត់វិធានការ។ នៅក្នុងករណីដែលក្រុមប្រឹក្សាភិបាលមិនបានទទួលការជំទាស់របស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរព្យាបាលនោះ ក្រុមប្រឹក្សាភិបាលត្រូវបង្ហាញហេតុផល ហើយត្រូវជូនដំណឹងទៅក្រសួងអាណាព្យាបាល ឬអាជ្ញាធរព្យាបាលវិញជាបន្ទាន់។ គណនីទាំងឡាយរបស់សហគ្រាសសាធារណៈ ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួត-ពិនិត្យពីអ្នកជំនាញគណនេយ្យ តាមលក្ខខណ្ឌ និងបែបបទដែលកំណត់ដោយអនុក្រឹត្យ។ លទ្ធកម្មដោយសហគ្រាសសាធារណៈ ដាច់ខាតត្រូវធ្វើឡើងដោយអនុលោមតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ វិធានការនៃការដេញថ្លៃ ការអនុវត្ត និងការត្រួតពិនិត្យការដេញថ្លៃត្រូវបានកំណត់ដោយអនុក្រឹត្យ[3]។

**១.១.២.៣. ការត្រួតពិនិត្យសហគ្រាសសាធារណៈ**:

ការត្រួតពិនិត្យសហគ្រាសសាធារណៈ ត្រូវធ្វើឡើងទៅតាមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈដែលជាគោលការណ៍ និងដោយក្រសួងអាណាព្យាបាល ដែលជាស្ថាប័នរដ្ឋសម្រាប់គ្រប់គ្រងសេវាសាធារណៈ ។

- **ស្ថាប័នរដ្ឋដែលគ្រប់គ្រងសេវាសាធារណៈ**

ក្រសួងអាណាព្យាបាល ឬអាជ្ញាធរព្យាបាល ត្រូវធ្វើការត្រួតពិនិត្យសេដ្ឋកិច្ចដល់សហគ្រាសតាមរយៈតំណាងរបស់ខ្លួនដែលនៅក្នុងក្រុមប្រឹក្សាភិបាល។ ការត្រួតពិនិត្យសេដ្ឋកិច្ច ត្រូវបានធ្វើឡើងដើម្បីធានាឲ្យសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល មានលក្ខណៈអនុលោមតាម

[3] ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦,មាត្រា១៤-មាត្រា១៩

ទិសដៅរបស់រដ្ឋាភិបាល ឬតាមការណែនាំរបស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរព្យាបាល។ មួយវិញទៀត ត្រូវបានដាក់ឲ្យនៅអមសហគ្រាសសាធារណៈនីមួយៗ នូវមន្ត្រីត្រួតពិនិត្យរដ្ឋដែលទទួលបន្ទុកខាងការងារត្រួតពិនិត្យជាអាទិ៍[4]៖

- ការបំពេញកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ ដែលមានចែងនៅក្នុងច្បាប់ និងបទបញ្ញាទាំងឡាយជាធរមាន
- ការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ការតាមដានការប្រព្រឹត្តទៅ និងការអភិវឌ្ឍរបស់សហគ្រាស
- ប្រក្រតីភាពនៃសកម្មភាពទាំងឡាយ ដែលអាចជះឥទ្ធិពលដល់ស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាស។

មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានតែងតាំងនិងបញ្ឈប់ពីតំណែងដោយអនុក្រឹត្យ តាមសំណើររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីជាន់ខ្ពស់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបាននិងកំពុងបម្រើការងារសាធារណៈយ៉ាងតិច ៥ឆ្នាំ។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបំពេញភារកិច្ចតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវរាយការណ៍ជូនក្រសួង ឲ្យបានទៀងទាត់អំពីការបំពេញភារកិច្ចរបស់ខ្លួន។ មន្ត្រីត្រួត-ពិនិត្យរដ្ឋ ត្រូវចូលរួមអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល មានសិទ្ធិផ្ដល់យោបល់ពិគ្រោះ និងត្រូវបានអញ្ជើញឲ្យចូលរួមក្នុងមហាសន្និបាតជាទៀងទាត់។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវផ្ដល់យោបល់លើបញ្ហាដែលមានចុះក្នុងរបៀបវារៈនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលក្នុងការអនុវត្តភារកិច្ចនេះ មន្ត្រីត្រួតពិនិត្យរដ្ឋអាចស្នើសុំពត៌មាន ឬស្វែងយល់នៅនឹងកន្លែងអំពីឯកសារ ឬបញ្ជីទាំងអស់ដែលមានក្នុងសហ-គ្រាស។ មន្ត្រីត្រួតពិនិត្យរដ្ឋ អាចជំទាស់នឹងការចាត់វិធានការទាំងឡាយដែលខ្លួនយល់ឃើញថាផ្ទុយនឹងច្បាប់ និងការប្រតិបត្តិដែលប៉ះពាល់ដល់សិទ្ធិនិងផលប្រយោជន៍របស់សហគ្រាស ឬរបស់រដ្ឋ ឬពុំសមស្របនឹងគោលដៅរបស់សហគ្រាស។ ការជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាល នៅពេលប្រជុំ ឬយ៉ាងយូរបំផុតក្នុងរយៈពេល ៣ថ្ងៃ"គិតតែថ្ងៃធ្វើការ"ក្រោយពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវរាយការណ៍ជាបន្ទាន់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាលបច្ចេកទេសនៃសហគ្រាស អំពីការជំទាស់របស់ខ្លួនលើការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា-ភិបាល។ ៩ថ្ងៃធ្វើការក្រោយការជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋ បើសិនជាក្រសួងសេដ្ឋកិច្ចនិង

[4] ច្បាប់ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦,មាត្រា២១-មាត្រា២៥

ហិរញ្ញវត្ថុ ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាល មិនបានបញ្ជាក់អំពីការជំទាស់នេះ ដោយចេញបញ្ជាឲ្យលុបចោលឬកែប្រែសេចក្តីសម្រេចនោះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវចាត់ទុកជាបានការ។

## ១.២. ទំនាក់ទំនងរវាងសហគ្រាសសាធារណៈ និងរដ្ឋ

### ១.២.១. ការត្រួតពិនិត្យរបស់រដ្ឋ

សហគ្រាសសាធារណៈជាច្រើន ជាទូទៅរកស៊ីមិនសូវបានចំណេញនោះទេដោយតម្រូវឲ្យរដ្ឋជួយឧបត្ថម្ភដែលជាហេតុនាំឲ្យរដ្ឋត្រូវតែពិនិត្យមើល។

- **ជំនួយហិរញ្ញវត្ថុរបស់រដ្ឋ**

សហគ្រាសសាធារណៈជាច្រើនតែងតែជួបបញ្ហា ហើយបញ្ហាធំបំផុតគឺបំណុលនេះបណ្តាលមកពីការគ្រប់គ្រងមិនល្អ ដូចជាការចំណាយច្រើនទៅលើសោធនិវត្តន៍ និងកិច្ចការដែលរដ្ឋបង្ខំឲ្យធ្វើខ្លះ។ មួយវិញទៀតរដ្ឋបានកំណត់ថ្លៃឲ្យអនុវត្ត ហើយតម្លៃនេះមានកម្រិតទាប មិនរួចសោហ៊ុយ។ ដើម្បីដោះស្រាយឱនភាពហិរញ្ញវត្ថុសហគ្រាសសាធារណៈ ភាគច្រើនរដ្ឋត្រូវខ្ចីលុយបរទេស ឬរដ្ឋឧបត្ថម្ភដោយខ្លួនឯងផ្ទាល់ ប្រសិនបើមានលទ្ធភាព។

# ជំពូកទី២
# ដំណើរការគ្រប់គ្រងរដ្ឋបាល
# កំពង់ផែស្វយ័តភ្នំពេញ

# ជំពូកទី២
# ដំណើរការគ្រប់គ្រងរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ

## ២.១. ស្ថានភាពទូទៅនៃកំពង់ផែស្វយ័តភ្នំពេញ

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ ឬ ក្រុមហ៊ុន) គឺជាប្រត្តិបត្តិករកំពង់ផែទន្លេធំជាងគេបំផុត និងជាកំពង់ផែកុងតឺន័រអន្តរជាតិធំជាងគេទីពីរនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក.ស.ភ គឺជាសហគ្រាសសាធារណៈដែលមានទម្រង់ជាក្រុមហ៊ុនរដ្ឋ ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ ៥១ អនក្រ.បក នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដែលស្ថិតនៅក្រោមអាណាព្យាបាលផ្នែកបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងអាណាព្យាបាលផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក.ស.ភ បានចុះបញ្ជីលក់មូលបត្រនៅលើផ្សារមូលបត្រកម្ពុជា (ផ.ម.ក) នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ដែលមានលេខចុះបញ្ជី ០០៣ CSX/SC និងប្រែក្លាយជាសហគ្រាសសាធារណៈដែលមានទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ។

កំពង់ផែស្វយ័តភ្នំពេញ ស្ថិតនៅទីតាំងភូមិសាស្ត្រប្រកបដោយសក្តានុពល និងយុទ្ធសាស្ត្រ ដោយនៅចំបេះដូងនៃរាជធានីភ្នំពេញដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ឧស្សាហកម្ម រោងចក្រ អ្នកប្រើប្រាស់ និងជាកន្លែងប្រមូលផ្តុំទៅដោយកម្លាំងពលកម្ម។ ការដឹកជញ្ជូនតាម ក.ស.ភ ផ្តល់ភាពងាយស្រួល រហ័ស និងចំណាយតិចក្នុងការចែកចាយ និងផ្គត់ផ្គង់ទំនិញដល់អ្នកប្រើប្រាស់។ ជាមួយគ្នានេះដែរទីតាំងរបស់ ក.ស.ភ គឺនៅជិត និងមានរយៈចម្ងាយនៃការដឹកជញ្ជូនជិតជាងចំណតផែដទៃទៀត នៅក្នុងប្រទេសកម្ពុជា ដូចជាការដឹកជញ្ជូនទំនិញឆ្លងកាត់ទៅកាន់ប្រទេសវៀតណាម ប្រទេសចិន ប្រទេសជប៉ុន និងសហរដ្ឋអាមេរិកជាដើម។ ដែលប្រទេសទាំង ០៤ នេះ គឺមានទំហំពាណិជ្ជកម្មធំ ជាមួយប្រទេសកម្ពុជាបើធៀបទៅនឹងប្រទេសដទៃទៀត[5]។

### ២.១.១. ប្រវត្តិកំពង់ផែស្វយ័តភ្នំពេញ

ប្រវត្តិរបស់ ក.ស.ភ អាចត្រូវបានបែងចែកជាពីរដំណាក់កាលសំខាន់ៗ៖

❖ **ដំណាក់កាលពីឆ្នាំ១៩០៥ ដល់ឆ្នាំ១៩៩៨**

- នៅឆ្នាំ១៩០៥ កំពង់ផែភ្នំពេញ ត្រូវបានបង្កើតឡើងដំបូងដោយមានចំណតផែបណ្តែតដែលមានប៉ង់តុងចំនួន ០២គ្រឿង មានបណ្តោយ៤០ម៉ែត្រ និងទទឹង១០ម៉ែត្រ។

- នៅឆ្នាំ១៩២៩ ប៉ង់តុង ០១គ្រឿងទៀត ដែលមានបណ្តោយ៤០ម៉ែត្រ និងទទឹង១០ម៉ែត្រ ត្រូវបានកសាងបន្ថែមជាប់នឹងប៉ង់តុងចាស់ទាំងពីរ។

[5] របាយការណ៍ប្រចាំឆ្នាំ ២០១៧ របស់កំពង់ផែស្វយ័តភ្នំពេញ

- នៅឆ្នាំ១៩៥២ ស្ពានផែជាបេតុងអាម៉េ មានបណ្តោយ ៨០ម៉ែត្រ និងទទឹង១២ម៉ែត្រត្រូវបាន សាងសង់ចម្ងាយប្រហែល ០១គីឡូម៉ែត្រពីប៉ង់តុងទាំងបី។ ស្ពានផែនេះអាចឲ្យនាវាចំណុះ ២.៥០០ តោន ចេញ-ចូល ផ្ទេរ និងផ្ទុកទំនិញ បានដោយងាយស្រួល។ តួស្ពានផែនេះអាចទទួលកម្លាំង សង្កត់ដល់ ០៦តោន ក្នុង០១ម៉ែត្រការ៉េ។ ស្ពានផែនេះមានជម្រៅទឹក ១០ម៉ែត្រ ធៀបនឹងនីវ៉ូទឹក សមុទ្រ។

- នៅឆ្នាំ១៩៦០ ស្ពានផែប្រវែង ១០០ម៉ែត្រ និង ទទឹង១២ម៉ែត្រ ត្រូវបានសាងសង់បន្ថែមជាប់ នឹងស្ពានផែចាស់។ ស្ពានផែនេះអាចទទួលកម្លាំងសង្កត់ពី ១០តោន ទៅ១២តោន ក្នុង០១ម៉ែត្រ ការ៉េ។ ស្ពានផែទាំងពីររួមគ្នាមានប្រវែង ១៨០ម៉ែត្រ និងទទឹង១២ម៉ែត្រដែលអាចទទួលនាវាពី ០២ គ្រឿង ទៅ០៣គ្រឿង ចូលចតក្នុងពេលតែមួយ។

- នៅដើមឆ្នាំ១៩៨០ ផែបណ្តែតដែលមានប៉ង់តុងចំនួន ០២គ្រឿង ប្រវែង៤៥ម៉ែត្រ និងទទឹង ១៥ម៉ែត្រ និងកម្ពស់០៣ម៉ែត្រ លិចទឹកជម្រៅ ០,៥ម៉ែត្រ និងខ្សែកុងវ៉ូយ័រសម្រាប់អូសទំនិញឡើងចុះ ត្រូវបានសាងសង់ជាថ្មី ដោយសារប៉ង់តុងចាស់បានខូចខាតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ផែ បណ្តែតនេះ មានសមត្ថភាពលើកដាក់បាន ៣០០តោនក្នុង ០១ថ្ងៃ។ ក.ស.ភ ត្រូវបានដំណើរការ ឡើងវិញ ក្នុងទម្រង់ជាមណ្ឌលផែ និងផែក្នុងស្រុករបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

- នៅឆ្នាំ១៩៩៥ ផែបណ្តែតនេះត្រូវបានរៀបចំជួសជុល ដោយផ្លាស់ប្តូរស្ពានចូលផែទាំងពីរ និងបានរៀបចំបំពាក់ភ្លើងអគ្គិសនី ប្រព័ន្ធបង្ហូរទឹកស្អាតចូលនាវា និងជួសជុលខ្សែកុងវ៉ូយ័រអូស ទំនិញ ចំនួន១៦ខ្សែ ដែលចំណាយទឹកប្រាក់ចំនួន ១.០៨៥.៥២៦ដុល្លារអាមេរិក ស្មើនឹង ៤.៣៨៣.៣៥៣.៩៨៨ រៀល ដោយប្រើប្រាស់ប្រាក់កម្ចីពីធនាគារពិភពលោក ហើយត្រូវបានដាក់ឲ្យ ប្រើប្រាស់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៩៦។

- ដោយសារស្ពានផែថ្មចាស់ទាំងពីរ ពុំអាចប្រើប្រាស់បានក្នុងឆ្នាំ ១៩៩៥ កំពង់ផែភ្នំពេញបាន កសាងស្ពានផែថ្មថ្មីមួយទៀត ដែលមានប្រវែង ៣០០ម៉ែត្រ និងទទឹង២០ម៉ែត្រសង់ជាប់ខាងក្រៅ ស្ពានផែចាស់នេះ ហើយមានលទ្ធភាពទទួលនាវាចូលចតបាន ០៤គ្រឿងក្នុងពេលតែមួយ និង ទទួលកម្លាំងសង្កត់បាន២៥តោន ក្នុង ០១ម៉ែត្រការ៉េ។ ការកសាងស្ពានផែថ្មថ្មីនេះ ជាជំនួយឥត សំណងពីរាជរដ្ឋាភិបាលនៃប្រទេសជប៉ុនក្នុងទឹកប្រាក់ ៣០.០០០.០០០ ដុល្លារអាមេរិកដែលគិតជា ប្រាក់រៀលស្មើនឹង ១២១.១៤០.០០០.០០០រៀល។ ក្រៅពីបានកសាងស្ពានផែថ្ម រាជរដ្ឋាភិបាលនៃ ប្រទេសជប៉ុន ក៏បានផ្តល់សម្ភារៈគ្រឿងចក្រដឹកជញ្ជូន និងសម្ភារៈលើកដាក់មួយចំនួនសម្រាប់បម្រើ ប្រតិបត្តិការរបស់កំពង់ផែភ្នំពេញផងដែរ។

❖ ដំណាក់កាលពីឆ្នាំ១៩៩៨ រហូតដល់បច្ចុប្បន្ន

- នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ កំពង់ផែស្វយ័តភ្នំពេញ ត្រូវបានបង្កើតឡើងក្នុងទម្រង់ជាសហគ្រាសសាធារណៈដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋ ដោយអនុក្រឹត្យលេខ ៥១ អនក្រ.បក។

- នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០១ ផែបណ្តែត(ប៉ង់តុងទាំងពីរគ្រឿង) ត្រូវបានកែប្រែឲ្យទៅជាចំណតផែអ្នកដំណើរ និងទេសចរណ៍សម្រាប់ទទួលនាវាដឹកអ្នកដំណើរនិងភ្ញៀវទេសចរណ៍ពីបណ្តាខេត្តមួយចំនួន ដូចជា កំពង់ចាម ក្រចេះ សៀមរាប ព្រៃវែង និងនាវាបរទេសឆ្លងកាត់ពីប្រទេសវៀតណាម និងប្រទេសដទៃទៀត។

- នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៧ ចំណតស្តុបកុងតឺន័រ ICD មានទំហំ៩,៣ហិចតា នៅភូមិបឹងសាឡាង សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកេវ រាជធានីភ្នំពេញ បានចាប់ផ្តើមប្រតិបត្តិការលើកដាក់ទំនិញកុងតឺន័រជាលើកដំបូង។ ចំណតស្តុបសំបកកុងតឺន័រនេះជាទីតាំងសម្រាប់វេចខ្ចប់ទំនិញ រើ និងរៀបចំទំនិញចេញចូលកុងតឺន័រ និងជាកន្លែងសម្រាប់ស្តុបសំបកកុងតឺន័រ។

- នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១២ កំពង់ផែស្វយ័តភ្នំពេញ បានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន មៀង លីហេង អ៊ិនវេសមិន ដើម្បីធ្វើប្រតិបត្តិការចំណតផែទន្លេបិទឡើងវិញ។ ក.ស.ភ ជាប្រតិបត្តិករផែនិងផ្តល់សេវាលើកដាក់ក្រោមដងយោង ចំណែកក្រុមហ៊ុនមៀង លីហេង អ៊ិនវេសមិនផ្តល់សេវាលើកដាក់ពីឃ្លាំងទៅមកទីលានផែ និងប្រតិបត្តិការឃ្លាំងស្តុបទុកទំនិញ។

- នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ កំពង់ផែស្វយ័តភ្នំពេញ បានផ្ទេរប្រតិបត្តិការចម្បងរបស់ខ្លួនពីចំណតផែពហុបំណង TS៣ ទៅចំណតផែកុងតឺន័រ LM១៧ ដែលមានចម្ងាយ ៣០គីឡូម៉ែត្រពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ ០១។ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ ចំណតផែកុងតឺន័រ LM១៧ នេះត្រូវបានដាក់សម្ពោធឲ្យប្រើប្រាស់ជាផ្លូវការ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ចំណតផែកុងតឺន័រLM១៧ នេះត្រូវបានបំពាក់ដោយឧបករណ៍ និងគ្រឿងចក្រលើកដាក់ទំនើបថ្មីៗ ហើយប្រតិបត្តិការផែត្រូវបានគ្រប់គ្រង ដោយប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការចំណតផែ TOS (Terminal Operation System) របស់ក្រុមហ៊ុន Phaeros Group BVBA (Phaeros) ។

### ២.១.២. មណ្ឌលអាជីវកម្មផែភ្នំពេញ

យោងតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សិទ្ធិផ្តាច់មុខជូន ក.ស.ភ ក្នុងប្រតិបត្តិការផែដែលស្ថិតក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ ដែលមានប្រវែង ១៦០គីឡូម៉ែត្រ លាតសន្ធឹងពីខេត្តត្បូងឃ្មុំ (ចំណតផែទន្លេបិទ UM២) ទៅដល់អ្នកលឿង។ ក្នុងនាមជាអាជ្ញាធរ ក.ស.ភ មានតួនាទីគ្រប់គ្រងចំណតផែឯកជននានា នៅក្នុង

មណ្ឌលអាជីវកម្ម ដោយរាប់បញ្ចូលទាំងចំណតផែប្រេង និងចំណតផែដទៃទៀត។ ដោយឡែក ក.ស.ភ គ្រប់គ្រងនិងប្រតិបត្តិការដោយផ្ទាល់ទៅលើចំណតផែចម្បងចំនួន ៤ ទៀតរួមមាន ចំណតផែកុងតឺន័រ LM១៧ ចំណតផែពហុបំណង TS៣ ចំណតផែទន្លេបិទ UM២ និងចំណតអ្នកដំណើរ និងទេសចរ TS១ [6]។

### ២.១.៣. តួនាទីរបស់កំពង់ផែស្វយ័តភ្នំពេញ

កំពង់ផែស្វយ័តភ្នំពេញ គឺជាអង្គភាពស្វយ័តដែលដើរតួនាទីសំខាន់ពីរនៅក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញគឺ អាជ្ញាធរផែ និងប្រតិបត្តិករផែ[7]។

❖ **ប្រតិបត្តិការក្នុងនាមជាអាជ្ញាធរផែ**

ក្នុងនាមជាអាជ្ញាធរផែ ក.ស.ភ មានតួនាទី៖

- បំពាក់ឧបករណ៍ជំនួយដល់ការធ្វើនាវាចរណ៍ដូចជា ពោងសញ្ញា និងបង្គោលសញ្ញា
- រៀបចំផែចូលចតដល់នាវា ថែទាំផ្លូវនាវាចរណ៍
- ថែរក្សាសុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់
- ធ្វើការបណ្តុះបណ្តាលធនធានមនុស្សផ្នែកនាវាចរណ៍
- ការពារបរិស្ថាន នៅក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ ដែលកំណត់ដោយអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩
- ចាត់វិធានការធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងវិស័យកំពង់ផែ និងការដឹកជញ្ជូននានាតាមផ្លូវទឹក។

❖ **ប្រតិបត្តិការក្នុងនាមជាប្រតិបត្តិករផែ**

ក្នុងនាមជាប្រតិបត្តិករផែ ក.ស.ភ មានភារកិច្ចបម្រើសេវាកម្មជាមូលដ្ឋានសំខាន់ៗរួមមាន៖

- សេវាកម្មផ្ទេរ-ផ្ទុក និងលើកដាក់ទំនិញ
- ការច្រកនិងរើទំនិញ ស្តុកទំនិញ
- ការដឹកជញ្ជូនទំនិញកុងតឺន័រ
- សេវាកម្មកណ្ណធារកិច្ចនាំនាវាចេញ-ចូលចំណតផែ
- សេវាកម្មចំណតផែអ្នកដំណើរ និង ទេសចរណ៍ TS១
- សេវាកម្មនាវាសណ្តោង និង សេវាកម្មពាក់/ដោះពួរនាវា ។

[6] របាយការណ៍ប្រចាំឆ្នាំ ២០១៦ របស់កំពង់ផែស្វយ័តភ្នំពេញ

[7] របាយការណ៍ប្រចាំឆ្នាំ ២០១៧ របស់កំពង់ផែស្វយ័តភ្នំពេញ

## ២.២. ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ

### ២.២.១. រចនាសម្ព័ន្ធនៃការគ្រប់គ្រង

បច្ចុប្បន្នកំពង់ផែស្វយ័តភ្នំពេញ មានក្រុមប្រឹក្សាភិបាលចំនួន០៧រូប មានអគ្គនាយក ១រូប អគ្គនាយករងចំនួន ០៤រូប ជាជំនួយការប្រធានអគ្គនាយក និងគណៈកម្មាធិការចំនួន៣ ។ ដោយឡែកនៅថ្នាក់ប្រតិបត្តិការ ក.ស.ភ មានចំនួន១១នាយកដ្ឋាន រួមទាំង៣៦ការិយាល័យ សេវាដ្ឋាន និង អង្គភាព។

#### ២.២.១.១. សមាសភាពក្រុមប្រឹក្សាភិបាល

យោងតាមអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយដើម្បីបំពេញមុខងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិនៃអនុក្រឹត្យនេះ និង បទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

សមាសភាពក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទរួមមាន៖

- ឯកឧត្តម ហ៊ី ប៉ាវី ប្រធាន និងជាអគ្គនាយក ក.ស.ភ
- ឯកឧត្តម សួន រចនា សមាជិក(តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន)
- ឯកឧត្តម កែន សម្បត្តិ សមាជិក(តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)
- ឯកឧត្តម ប៉ែន សុវិជាតិ សមាជិក(តំណាងក្រសួងពាណិជ្ជកម្ម)
- លោក ហ្គី អានវ៉ានិថ សមាជិក(តំណាងអភិបាលឯករាជ្យ)
- លោកស្រី ជួន សុខេម សមាជិក(តំណាងនិយោជិត ក.ស.ភ)
- លោក ឌិត សុចល សមាជិក(តំណាងអភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន)

ក្រុមប្រឹក្សាភិបាលមានតួនាទីនិងភារកិច្ចកំណត់ទិសដៅអភិវឌ្ឍ និងត្រួតពិនិត្យការគ្រប់គ្រងទូទៅរបស់កំពង់ផែស្វយ័តភ្នំពេញ។ ក្នុងក្របខណ្ឌនេះ ក្រុមប្រឹក្សាភិបាលមានអំណាចដូចខាងក្រោម៖

- សម្រេចលើផែនការអភិវឌ្ឍ ក្នុងក្របខណ្ឌនៃការតម្រង់ទិស កំណត់ដោយរាជរដ្ឋាភិបាល
- ពិនិត្យអនុម័តផែនការអាជីវកម្ម សេវាកម្ម ផែនការហិរញ្ញវត្ថុ និងវិនិយោគរបស់ ក.ស.ភ
- អនុម័តលើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍គណនេយ្យ ហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការចាត់ចែង និងភារកិច្ចទូទៅរបស់ ក.ស.ភ
- ចាត់ចែងឲ្យដំណើរការនូវគណៈកម្មាធិការ និងគណៈកម្មការដូចមានកំណត់ដោយអត្ថបទស្តីពីការបង្កើត ក.ស.ភ ឬដោយលក្ខន្តិកៈរបស់ ក.ស.ភ និងបង្កើតបន្ថែមទៀតប្រសិនបើចាំបាច់

- សម្រេចចំនួនក្របខណ្ឌបុគ្គលិក ដែលអនុញ្ញាតសម្រាប់ ក.ស.ភ
- វាយតម្លៃក្នុងចន្លោះពេលទៀងទាត់ នូវកម្រិតទំហំនៃការធ្វើឲ្យសម្រេចនូវគោលដៅដែលកំណត់ដោយ ក.ស.ភ និងដាក់ចុះនូវវិធានការសម្រាប់កែលម្អចាំបាច់
- សម្រេចតាមសំណើររបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់ ក.ស.ភ ព្រមទាំងលក្ខន្តិកៈ និងកាំបៀរវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ និងលាភការសម្រាប់បុគ្គលិកដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន
- កំណត់របបផែនការជ្រើសរើស ការតម្លើងឋានៈ និងការផ្តល់លាភការសម្រាប់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់
- ជ្រើសរើស និងកំណត់លាភការសម្រាប់ផ្តល់ឲ្យស្នងការគណនី
- ធ្វើសំណើរកែសម្រួលលក្ខន្តិកៈ
- កំណត់ថ្លៃឈ្នួលពាក់ព័ន្ធនិងការធ្វើអាជីវកម្ម សេវាកម្មលើកំពង់ផែ
- អនុម័តលើលទ្ធកម្មនានា យោងតាមច្បាប់ និងបទបញ្ញត្តិជាធរមាន
- សម្រេចលើការបើក និងបិទគ្រប់ការិយាល័យ សេវាដ្ឋាន សាខា ទីភ្នាក់ងារ ឬតំណាងទាំងអស់ដែលចាំបាច់សម្រាប់អនុវត្តឲ្យសម្រេចគោលដៅ និងភារកិច្ចរបស់ ក.ស.ភ
- អនុម័តលើកិច្ចសន្យាទាំងឡាយណា ដែលពុំអាចអនុវត្តតាមតារាងថ្លៃឈ្នួល និងតាមប្រកាសស្តីពីការគ្រប់គ្រងលទ្ធកម្មនៃសហគ្រាសសាធារណៈ ដែលអគ្គនាយកឆ្លងយោបល់ក្រុមប្រឹក្សាភិបាល។

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីសកម្ម ធ្លាប់បានបម្រើការងារយ៉ាងតិច ០៥(ប្រាំឆ្នាំ) ឬជាឥស្សរជន ដែរមានអាយុមិនលើសពី ៦៥ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ចវិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្ម ព្រហ្មទណ្ឌកម្រិតធ្ងន់ពីតុលាការឡើយ។ សមាជិកក្រុម-ប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣(បី)ឆ្នាំ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបាន ដោយអនុក្រឹត្យតាមសំណើររបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឲ្យ។ តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិត ក.ស.ភ ។

➢ **ការបញ្ចប់អាណត្តិ**

ក្រោយពីបញ្ចប់ភារកិច្ចរបស់ខ្លួន អភិបាលនិងបុគ្គលិកជាន់ខ្ពស់ ដែលចូលនិវត្តន៍ត្រូវប្រគល់ភ្លាមទៅឲ្យ ក.ស.ភ វិញនូវឯកសារអេឡិចត្រូនិច និងឯកសារជាក្រដាស ឯកសារយោង និងឯកសារផ្សេងៗទៀត ដែលត្រូវបានផ្តល់ជូនក្នុងគោលបំណងបំពេញការងារ។ ការប្រគល់ជូនទៅ

វិញនូវឯកសារទាំងនេះ មិនបានលុបចោលនូវកាតព្វកិច្ចរក្សាការសម្ងាត់នូវពត៌មាន ដែលទទួលបាន ក្នុងរយៈពេលនៃការកាន់មុខតំណែងនៅក្នុងក្រុមប្រឹក្សាភិបាល ឬតួនាទីជាន់ខ្ពស់នៅក្នុង ក.ស.ភ នោះទេ។

**២.២.១.២. គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល**

នៅឆ្នាំ២០១៦ ក.ស.ភ បានចេញសេចក្តីសម្រេចលេខ ០៦៦២ ក.ស.ភ/PPAP ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការចំនួន២ ដែលរួមមាន គណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ។

- **គណៈកម្មាធិការសវនកម្ម**

គណៈកម្មាធិការសវនកម្ម មានសមាសភាពចំនួន ៥រូបដឹកនាំដោយប្រធាន ១រូបជាអភិបាលឯករាជ្យ អនុប្រធាន ១រូបជាមន្ត្រីត្រួតពិនិត្យរដ្ឋ និងមានសមាជិកចំនួន ៣រូបទៀត ដែលក្នុងនោះមានអគ្គនាយករងប្រតិបត្តិការ/អាជីវកម្មចំនួន ១រូប ប្រធាននាយកដ្ឋានផែនការ/ទីផ្សារចំនួន ១រូប និងមានប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងចំនួន ១រូបដែល។ គណៈកម្មាធិការនេះមាន តួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ
- ពិនិត្យការត្រួតពិនិត្យផ្ទៃក្នុង
- ពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង
- ពិនិត្យការធ្វើសវនកម្មខាងក្រៅ
- រាយការណ៍ជូនក្រុមប្រឹក្សាភិបាលពីសកម្មភាពរបស់ខ្លួន
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

- **គណៈកម្មាធិការគ្រប់គ្រងហានិភ័យ**

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ មានសមាសភាពចំនួន ៥រូប ដឹកនាំដោយប្រធានអគ្គ-នាយកឬអគ្គនាយក ១រូបជាប្រធាន អភិបាលតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូបជាអនុប្រធាន និងមានសមាជិកចំនួន ៣រូបទៀតក្នុងនោះមាន អភិបាលតំណាងក្រសួងពាណិជ្ជកម្មចំនួន ១រូប អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនចំនួន ១រូប និងមានអគ្គនាយករងកិច្ច-ការផែចំនួន ១រូបផងដែរ។ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ មានតួនាទី និងមានភារកិច្ចដូចខាងក្រោម៖

- ការវិភាគហានិភ័យរួមមាន ការពិពណ៌នាហានិភ័យ ការកំណត់អត្តសញ្ញាណហានិភ័យ ការប៉ាន់ស្មានហានិភ័យ

- ការវាយតម្លៃអំពីហានិភ័យ
- ការលើកវិធានការទប់ទល់ហានិភ័យ
- ការតាមដានអំពីហានិភ័យ
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

សម្រាប់ឆ្នាំ២០១៧ ក.ស.ភ ក៏បានបង្កើតគណៈកម្មាធិការដែរ គឺគណៈកម្មាធិការតែងតាំង។

➢ **គណៈកម្មាធិការតែងតាំង**

គណៈកម្មាធិការតែងតាំង មានសមាសភាពចំនួន ៣រូប ដឹកនាំដោយអភិបាលតំណាងក្រសួងសាធារណការនិងដឹកជញ្ជូន ១រូបជាប្រធាន អភិបាលតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូបជាអនុប្រធាន និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ១រូបជាសមាជិក ។ គណៈកម្មាធិការតែងតាំង មានតួនាទី និងភារកិច្ចដូចខាងក្រោមៈ

- ការពិនិត្យ និងការវាយតម្លៃគុណវុឌ្ឍិ បេក្ខភាពដែលត្រូវតែងតាំងតាមរយៈការសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ការរៀបចំនីតិវិធី ឬការពិនិត្យឡើងវិញ និងការផ្តល់អនុសាសន៍សម្រាប់លាភការ និងប្រាក់បំណាច់របស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

**២.២.១.៣. អគ្គនាយក**

ក្នុងនាមជាអគ្គនាយក មានតួនាទី និងភារកិច្ចដូចខាងក្រោមៈ

- រៀបចំការប្រជុំនៃក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកប្រតិបត្តិនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និង ការដាក់ឲ្យអនុវត្តនូវគោលនយោបាយដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ក.ស.ភ ហើយដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័ត
- រៀបចំរបាយការណ៍សកម្មភាពប្រចាំឆ្នាំ និង របាយការណ៍គណនេយ្យ/ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័ត
- អនុវត្តតួនាទីជាអាជ្ញាធរ ដើម្បីគ្រប់គ្រងសណ្តាប់ធ្នាប់ទូទៅក្នុងមណ្ឌលអាជីវកម្មផែរបស់កំពង់ផែស្វយ័តភ្នំពេញ
- កំណត់ចំនួនក្របខណ្ឌបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល និងគោរពទៅតាមលក្ខន្តិកៈបុគ្គលិក
- អនុវត្តឋានានុក្រមរបស់ ក.ស.ភ ចំពោះបុគ្គលិកទាំងអស់

- សម្រេច និងចុះហត្ថលេខាលើកិច្ចសន្យា ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុម-ប្រឹក្សាភិបាលស្តីពីការបែងចែកអំណាច
- បំពេញកិច្ចការទូទៅក្នុងដំណើរការមុខងាររដ្ឋបាលនិងការគ្រប់គ្រង ដែលចាំបាច់ក្នុងដំណើរការប្រក្រតីរបស់ ក.ស.ភ ។

**២.២.១.៤. អគ្គនាយករង**

អគ្គនាយករងរបស់ ក.ស.ភ មានចំនួន ០៤ រូប ដែលជាជំនួយការប្រធានអគ្គនាយកនិងទទួលបន្ទុកការងារទៅតាមផ្នែករបស់ខ្លួន។

- ទទួលបន្ទុកការងាររដ្ឋបាល/ហិរញ្ញវត្ថុ
- ទទួលបន្ទុកការងារបច្ចេកទេស
- ទទួលបន្ទុកការងារកិច្ចការផែ និងចរាចរណ៍នាវា
- ទទួលបន្ទុកការងារអាជីវកម្ម/ប្រត្តិបត្តិការផែ

**២.២.១.៥. ប្រធាននាយកដ្ឋាន**

ប្រធាននាយកដ្ឋានរបស់ ក.ស.ភ មានចំនួន១១រូប។ ក្នុងនាមជាប្រធាននាយកដ្ឋាននីមួយៗមានតួនាទី និងទំនួលខុសត្រូវទៅលើការងារបីប្រភេទរបស់ខ្លួនគឺ ការងារគ្រប់គ្រង ការងារជំនាញ និងការងារវាយតម្លៃ។ តួនាទី និងទំនួលខុសត្រូវរបស់ប្រធាននាយកដ្ឋាននីមួយៗរួមមានដូចខាងក្រោម[8]៖

❖ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

• ***ការងារគ្រប់គ្រង***

- ជាសេនាធិការដ្ឋានផ្ទាល់ឲ្យអគ្គនាយក លើការងារសវនកម្ម
- ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។

• ***ការងារជំនាញ***

- រៀបចំផែនការកម្មវិធីចុះធ្វើសវនកម្មប្រចាំឆ្នាំ
- ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ឲ្យស្របតាមស្តង់ដារ គណនេយ្យអន្តរជាតិ(CIFRS)
- ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ
- ធ្វើសវនកម្មលើការគ្រប់គ្រង និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
- ធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីអំពីការចុះធ្វើសវនកម្មជូនថ្នាក់ដឹកនាំជ្រាប និងមានវិធានការកែលម្អចំណុចខ្វះខាត

---

[8] របាយការណ៍ប្រចាំឆ្នាំ ២០១៧ របស់កំពង់ផែស្វយ័តភ្នំពេញ

- ធ្វើអធិការកិច្ចលើកិច្ចការសង្ស័យ ឬវិវាទណាមួយដែលចង្អុលបង្ហាញដោយអគ្គនាយក
- សម្របសម្រួលការងារសវនកម្មជាមួយនឹងសវនកម្មផ្ទៃក្រៅ។

• ***ការងារវាយតម្លៃ***

- ពិនិត្យ និងតាមដានផែនការដែលបានដាក់ចេញ
- តាមដានការអនុវត្តសកម្មភាព ឬអនុសាសន៍កែលម្អលើចំណុចខ្វះខាតរបស់អង្គភាពដែលរកឃើញដោយសវនកម្មផ្ទៃក្រៅ ឬសវនកម្មជំនាញ
- តាមដាន ត្រួតពិនិត្យគោលការណ៍ណែនាំ ឬគោលនយោបាយដែលដាក់ចេញដោយអង្គភាពពិនិត្យ និងវាយតម្លៃសកម្មភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងតួនាទី ការដាក់ពិន័យ ឬមានវិធានការដោះស្រាយ
- រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ ប្រធាននាយកដ្ឋានរដ្ឋបាល

• ***ការងារគ្រប់គ្រង***

- ជាសេនាធិការឲ្យអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ លើការងាររដ្ឋបាល ការងារសន្តិសុខឬសណ្តាប់ធ្នាប់ និងការងារព័ត៌មានវិទ្យា
- អនុវត្ត និងតាមដាននូវការគោរពបទបញ្ជាផ្ទៃក្នុងរបស់ ក.ស.ភ។

• ***ការងារជំនាញ***

- ត្រួតពិនិត្យ និងរៀបចំតាក់តែងឯកសាររដ្ឋបាល
- គ្រប់គ្រងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ ក.ស.ភ
- រៀបចំសេវាផ្តល់ពត៌មានអំពីសេវាកម្មរបស់ ក.ស.ភ ជូនអតិថិជន
- ធ្វើទំនាក់ទំនង និងសហការជាមួយស្ថាប័នរដ្ឋ-ឯកជន ដែលពាក់ព័ន្ធនិងវិស័យគ្រប់គ្រងថែរក្សា និងការពារទ្រព្យសម្បត្តិទាំងឡាយ ព្រមទាំងការរៀបចំបញ្ជីសារពើភ័ណ្ឌរបស់ ក.ស.ភ
- ត្រួតពិនិត្យ និងរៀបចំសំណើសុំទិញ និងសំណើសុំដកសាច់ប្រាក់រាល់ការចំណាយរដ្ឋបាល និងទិញសម្ភារៈការិយាល័យ សម្រាប់ប្រើប្រាស់ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- រៀបចំទីកន្លែងប្រជុំ និងការងារពិធីការសម្រាប់គ្រប់កម្មវិធីរបស់ ក.ស.ភ
- ត្រួតពិនិត្យគ្រប់គ្រង និងថែទាំប្រព័ន្ធទឹក និងប្រព័ន្ធអគ្គិសនី ព្រមទាំងអនាម័យ

- គ្រប់គ្រង និងត្រួតពិនិត្យលើការប្រើប្រាស់ប្រេងឥន្ធនៈ
- គ្រប់គ្រង និងចាត់ចែងការងារអន្តរាគមន៍រួម និងការពារសណ្តាប់ធ្នាប់ជូនថ្នាក់ដឹកនាំ និងបុគ្គលិករបស់ ក.ស.ភ
- រៀបចំបទបញ្ជាផ្ទៃកសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់របស់ ក.ស.ភ
- ដឹកនាំ ត្រួតពិនិត្យការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធព័ត៌មានវិទ្យា ការបែងចែកសិទ្ធិប្រើប្រាស់អ៊ិនធឺណែត និងបណ្តាញ Network សម្រាប់អង្គភាពនានា និងការតបណ្តាញប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាព
- សម្របសម្រួល និងដោះស្រាយវិវាទនានាពាក់ព័ន្ធការងាររដ្ឋបាល។

• ***ការងារវាយតម្លៃ***

- វាយតម្លៃនិងគ្រប់គ្រងការងារបុគ្គលិកក្រោមឱវាទ អនុលោមតាមច្បាប់ការងារ និងលក្ខន្តិកៈសហគ្រាស ព្រមទាំងលក្ខន្តិកៈបុគ្គលិករបស់ ក.ស.ភ
- ពិនិត្យ និងវាយតម្លៃសមត្ថភាពការងារបុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ និងការដាក់ពិន័យ
- ពិនិត្យ និងវាយតម្លៃដំណើរការប្រព្រឹត្តទៅនៃការងាររដ្ឋបាល ការងារសន្តិសុខ និងការងារព័ត៌មានវិទ្យាជូនថ្នាក់ដឹកនាំដើម្បីជ្រាប និងមានវិធានការដោះស្រាយ
- ពិនិត្យ និងវាយតម្លៃលើសំណើសុំផ្សេងៗពីគ្រប់អង្គភាព ដែលពាក់ព័ន្ធនឹងការចំណាយរដ្ឋបាលជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច
- ពិនិត្យ និងវាយតម្លៃលើគម្រោងរៀបចំកម្មវិធីជប់លៀងអាហារសាមគ្គី និងរង្វាន់លើកទឹកចិត្តប្រចាំឆ្នាំរបស់ ក.ស.ភ
- ពិនិត្យ និងវាយតម្លៃលើទិញសម្ភារៈការិយាល័យ ប្រើប្រាស់ក្នុងនាយកដ្ឋានចំណុះនិងគម្រោងរៀបចំឯកសណ្ឋានប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ និងបុគ្គលិករបស់ ក.ស.ភ
- តាមដាន និងវាយតម្លៃ ព្រមទាំងបូកសរុបជារបាយការណ៍ការងាររដ្ឋបាលជូនថ្នាក់ដឹកនាំជ្រាប និងមានវិធានការដោះស្រាយ។

❖ ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស

• ***ការងារគ្រប់គ្រង***

- ជាសេនាធិការឲ្យអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ លើការងារធនធានមនុស្ស និងការងារបណ្តុះបណ្តាល
- ពិនិត្យ និងតាមដានការគោរពនូវបទបញ្ជាផ្ទៃក្នុងរបស់ ក.ស.ភ

- គ្រប់គ្រងជីវប្រវត្តិ និងពិនិត្យរាល់សកម្មភាពការងាររបស់បុគ្គលិក ក.ស.ភ។

• ***ការងារជំនាញ***

- ធានាដំណើរការនៃការគ្រប់គ្រងបុគ្គលិក ដោយអនុលោមទៅតាមលក្ខន្តិកៈ ក.ស.ភ និង លក្ខន្តិកៈបុគ្គលិក ក.ស.ភ ព្រមទាំងច្បាប់ការងារ
- រៀបចំប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស ប្រាក់បៀវត្ស ប្រាក់បន្ថែមម៉ោង ប្រាក់រង្វាន់សរសើរប្រចាំឆ្នាំជូនបុគ្គលិក ក.ស.ភ
- គ្រប់គ្រងបញ្ជីវត្តមានបុគ្គលិក ក.ស.ភ
- រៀបចំសំណុំបែបបទនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ គ្រោះថ្នាក់ការងារ មរណភាព
- ពិនិត្យ និងធ្វើដំណើរលើការងារតម្លើងកាំថ្នាក់ប្រចាំឆ្នាំជូនបុគ្គលិក ក.ស.ភ
- ពិនិត្យ ផ្តល់យោបល់ជូនថ្នាក់ដឹកនាំលើសំណើព្យួរការងារ ផ្ទេរការងារ ការតម្លើងតួនាទី
- រៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្សទាំងក្នុង និងក្រៅប្រទេស
- រៀបចំជ្រើសរើសបុគ្គលិកតាមផែនការប្រចាំឆ្នាំរបស់ ក.ស.ភ។

• ***ការងារវាយតម្លៃ***

- ពិនិត្យ និងវាយតម្លៃលើសមត្ថភាព និងសកម្មភាពការងាររបស់បុគ្គលិក ក.ស.ភ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ឬតម្លើងតួនាទី។

❖ ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ

• ***ការងារគ្រប់គ្រង***

- ជាសេនាធិការឲ្យអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ លើការងារគណនេយ្យ និងហិរញ្ញវត្ថុ
- ផ្តល់ការណែនាំ និងកំណត់ទិសដៅការងាររបស់អង្គភាពក្រោមឱវាទ។

• ***ការងារជំនាញ***

- ត្រួតពិនិត្យលើផែនការអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុប្រចាំឆ្នាំ
- ត្រួតពិនិត្យការព្យាករណ៍ហិរញ្ញវត្ថុ
- ត្រួតពិនិត្យចំណុចដែលអាចកាត់បន្ថយចំណាយ និងធ្វើឲ្យមានភាពប្រសើរឡើង
- អនុវត្តគោលនយោបាយ និងនីតិវិធីចុះបញ្ជីការគណនេយ្យរបស់អង្គភាព
- អនុវត្តគោលការណ៍នៃការប្រមូលចំណូល និងបំណុលពីអតិថិជន
- ធានាការបង់ពន្ធរបស់អង្គភាពឲ្យបានទាន់ពេលវេលាតាមការកំណត់របស់ច្បាប់ពន្ធដារ
- គ្រប់គ្រង និងត្រួតពិនិត្យសាច់ប្រាក់(ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ)
- ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់គណនីធនាគាររបស់អង្គភាព (ប្រចាំខែ)

- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- វិភាគ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំលើលទ្ធផលហិរញ្ញវត្ថុ និងបម្រែបម្រួល ព្រមទាំងប្រត្តិបត្តិការអាជីវកម្មរបស់អង្គភាព។

• *ការងារវាយតម្លៃ*

- តាមដានត្រួតពិនិត្យគោលការណ៍ណែនាំ ឬគោលនយោបាយគណនេយ្យ
- ធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងនីតិវិធីចុះបញ្ជីការគណនេយ្យប្រចាំឆ្នាំ
- ពិនិត្យនិងវាយតម្លៃសកម្មភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងតួនាទី ការដាក់ពិន័យ ឬមានវិធានការដោះស្រាយ
- រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ ប្រធាននាយកដ្ឋានវិស្វកម្ម

• *ការងារគ្រប់គ្រង*

- ជាសេនាធិការឲ្យអគ្គនាយករងបច្ចេកទេស លើការងារបច្ចេកទេស រួមមានការងារហេដ្ឋា-រចនាសម្ព័ន្ធ និងមធ្យោបាយគ្រឿងចក្រ
- ផ្តល់ការណែនាំ និងកំណត់ទិសដៅការងាររបស់អង្គភាពក្រោមឱវាទ។

• *ការងារជំនាញ*

- រៀបចំកំណត់ស្តង់ដារបច្ចេកទេសសម្រាប់ហេដ្ឋារចនាសម្ព័ន្ធផែ និងមធ្យោបាយគ្រឿងចក្ររបស់ក.ស.ភ
- សិក្សា និងរៀបចំលើគម្រោងអភិវឌ្ឍផែលើផ្នែកបច្ចេកទេស
- ត្រួតពិនិត្យ ថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផែ និងមធ្យោបាយគ្រឿងចក្រ
- រៀបចំផែនការសម្ភារៈ និងគ្រឿងបន្លាស់សម្រាប់ការជួសជុលហេដ្ឋារចនាសម្ព័ន្ធផែ និងមធ្យោបាយគ្រឿងចក្រ។

• *ការងារវាយតម្លៃ*

- ពិនិត្យ និងវាយតម្លៃសកម្មភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងតួនាទី ការដាក់ពិន័យ ឬមានវិធានការដោះស្រាយ
- ដឹកនាំការប្រជុំរៀងរាល់ខែ ដើម្បីដកពិសោធន៍លើការងារជំនាញបច្ចេកទេសវិស្វកម្ម។

❖ ប្រធាននាយកដ្ឋានជលធារសាស្ត្រ

• *ការងារគ្រប់គ្រង*

- ជាសេនាធិការឲ្យអគ្គនាយករងបច្ចេកទេស លើការងារជលធារសាស្ត្រ រួមមានការងារវាស់ស្ទង់ ការងារបំពាក់ពោងសញ្ញា និងការងារបូមស្តារប្រឡាយ
- ផ្តល់ការណែនាំ និងកំណត់ទិសដៅការងាររបស់អង្គភាពក្រោមឱវាទ។

• *ការងារជំនាញ*

- រៀបចំផែនការប្រចាំឆ្នាំលើការងារវាស់ស្ទង់ និងការងារបូមស្តារប្រឡាយនាវាចរណ៍
- រៀបចំគម្រោងផែនការប្រចាំឆ្នាំលើការបំពាក់ ការថែទាំ និងការជួសជុលពោងសញ្ញា និងបង្គោលសញ្ញាតាមផ្លូវនាវាចរណ៍ក្នុងដែនអាជីវកម្មរបស់ ក.ស.ភ
- សិក្សា និងវាស់ស្ទង់ជម្រៅទឹកនៅក្នុងមណ្ឌលអាជីវកម្ម និងទីតាំងអភិវឌ្ឍរបស់ ក.ស.ភ
- អនុវត្តការងារបូមស្តារប្រឡាយនាវាចរណ៍ និងការបូមខ្សាច់ធ្វើអាជីវកម្ម
- គ្រប់គ្រងលើមធ្យោបាយបូមស្តារ និងមធ្យោបាយអូសទាញគ្រឿងចក្រ
- បំពាក់ពោងសញ្ញា និងបង្គោលសញ្ញាតាមផ្លូវនាវាចរណ៍ក្នុងមណ្ឌលអាជីវកម្ម
- គ្រប់គ្រង ថែរក្សា និងជួសជុលពោងសញ្ញា បង្គោលសញ្ញា តាមផ្លូវនាវាចរណ៍ក្នុងមណ្ឌលអាជីវកម្មរបស់ ក.ស.ភ។

• *ការងារវាយតម្លៃ*

- ពិនិត្យ និងវាយតម្លៃសកម្មភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងតួនាទី ការដាក់ពិន័យ
- សិក្សាស្រាវជ្រាវបច្ចេកទេស និងឧបករណ៍វាស់ស្ទង់គ្រប់ប្រភេទ
- ប្រមូលចងក្រងព័ត៌មាន និងឯកសារនានាពាក់ព័ន្ធនឹងផ្នែកជលធារសាស្ត្រ
- រៀបចំបូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីរាយការណ៍ជូនអគ្គនាយក ក.ស.ភ។

❖ ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍

• *ការងារគ្រប់គ្រង*

- ជាសេនាធិការឲ្យអគ្គនាយករងកិច្ចការផែ លើការងារនាវាចរណ៍ ការងារកណ្ណធារ និងការងារ SHE (Safety,Health and Environment)
- ផ្តល់ការណែនាំ និងកំណត់ទិសដៅការងាររបស់អង្គភាពក្រោមឱវាទ។

• *ការងារជំនាញ*

- ធានាការពារសុវត្ថិភាពដែនទឹកកំពង់ផែ និងគ្រប់គ្រងចលនានាវា
- តាមដានត្រួតពិនិត្យការបំពុលទឹក

- អនុវត្តបទបញ្ជា និងផ្តល់ការឯកភាពលើសកម្មភាពផ្សេងៗក្នុងតំបន់កំពង់ផែ
- ធានាសុវត្ថិភាពប្រត្តិបត្តិការកំពង់ផែ និងនាវាទាំងឡាយនៅកំពង់ផែ
- ដឹកនាំគណៈកម្មការធ្វើបែបបទចេញ/ចូលកំពង់ផែរបស់នាវា
- ធ្វើការណែនាំអំពីករណីនាវាដឹកជញ្ជូនទំនិញគ្រោះថ្នាក់
- បដិសេធមិនឲ្យនាវាចាកចេញពីកំពង់ផែ ក្នុងករណីមិនទូទាត់ប្រាក់កម្រៃ/ថ្លៃប្រើប្រាស់សេវា-កម្មផ្សេងៗ
- ផ្តល់លិខិតអនុញ្ញាតចេញពីកំពង់ផែ(Port clearance)ដល់នាវា
- បញ្ជូនវិញ្ញាបនបត្រដល់អង្គភាពពាក់ព័ន្ធ និង បញ្ជូនវិញ្ញាបនបត្រប៉ាន់ស្មានសេវាកម្មទៅការិយាល័យកិច្ចការជំនួយដើម្បីចេញវិក្កយបត្រផ្លូវការជូនអតិថិជន
- បែងចែកកណ្តាធារនាំផ្លូវនាវាចូល-ចេញ ក្នុងមណ្ឌលអាជីវកម្ម និងតាមបណ្តាខេត្តផ្សេងៗ
- គ្រប់គ្រង និងចាត់ចែងមធ្យោបាយនាវាសណ្តោង និងមធ្យោបាយនាវាចម្លង
- ពិនិត្យ និងបញ្ជូនពត៌មានមកដល់ និងចេញដំណើររបស់នាវា ដែលបានពីទីភ្នាក់ងារកម្ពុជានាវាចរណ៍កាំសាបឲ្យទៅអង្គភាពពាក់ព័ន្ធអនុវត្ត
- រៀបចំ និងគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយ សន្តិសុខ និងសុវត្ថិភាពរបស់នាវាចរណ៍ និងបរិស្ថានល្អក្នុងមណ្ឌលអាជីវកម្ម
- ចាត់ចែងសកម្មភាពនាវាតាមផែក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ និងចំណតផែអ្នកដំណើរ
- ណែនាំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយសុវត្ថិភាព សុខមាលភាព និងបរិស្ថានផែធានាឲ្យដំណើរការប្រតិបត្តិការផែអនុលោមតាមស្តង់ដារអន្តរជាតិជាអាទ៍SHE (Safety,Health and Environment) ISPS Code IMDG Cods
- ប្រតិបត្តិច្បាប់តាមបទប្បញ្ញត្តិជាតិ-បទប្បញ្ញត្តិអន្តរជាតិលើនាវាជាតិអន្តរជាតិ និងចំណតផែ

- ***ការងារវាយតម្លៃ***

- ពិនិត្យ និងវាយតម្លៃសកម្មភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ ការដាក់ពិន័យ
- វាយតម្លៃរាល់ការប៉ះទង្គិចគ្រោះថ្នាក់ដែលបណ្តាលឲ្យខូចខាតនាវាសាឡង់ និងចំណតផែដែលស្ថិតនៅក្នុងព្រំប្រទល់ផ្ទៃទឹកកំពង់ផែ មណ្ឌលផែ ជូនថ្នាក់ដឹកនាំជ្រាប និងមានដំណោះស្រាយ
- តាមដានសកម្មភាពច្រាំងទន្លេ និងសកម្មភាពយកដីពីបាតទន្លេ និងផលប៉ះពាល់ក្នុងការកសាងផែ និងចំណតផែដែលមានស្រាប់

- តាមដានពិនិត្យកំពស់ទឹកឡើងចុះប្រចាំថ្ងៃ និងផ្តល់ជម្រៅទឹកប្រចាំខែ ដល់ស្ថាប័នពាក់ព័ន្ធនានា តាមរយៈទីភ្នាក់ងារនាវាចរណ៍កាំសាប សម្រាប់ការកំណត់ជម្រៅស៊ីទឹករបស់នាវាចេញ-ចូល ក.ស.ភ
- រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែភ្នំពេញ/ផែក្នុងស្រុក

• ***ការងារគ្រប់គ្រង***

- ជាសេនាធិការឲ្យអគ្គនាយករងកិច្ចការផែ លើការងារមណ្ឌលផែ/ផែក្នុងស្រុក ការងារផែទេសចរណ៍ ការងារចំណតផែទន្លេបិទ និងការងារផែប្រេង/ហ្គាស
- ផ្តល់ការណែនាំ និងកំណត់ទិសដៅការងាររបស់អង្គភាពក្រោមឱវាទ។

• ***ការងារជំនាញ***

- រៀបចំផែនការគ្រប់គ្រង និងរៀបចំសណ្តាប់ធ្នាប់ និងចំណតផែក្នុងមណ្ឌលអាជីវកម្មផែកាណូតផ្សេងៗ
- គ្រប់គ្រងចំណតចេញ-ចូលនាវា នាវាទេសចរណ៍ជាតិ និងអន្តរជាតិ គ្រប់គ្រងចំណតរថយន្តច្រកទ្វារចេញ-ចូល ប្រមូលថ្លៃឈ្នួល រៀបចំសណ្តាប់ធ្នាប់នាវាដឹកអ្នកដំណើរនៅផែបណ្តែត
- គ្រប់គ្រងចំណតផែទន្លេបិទលើការងារប្រតិបត្តិការ និងដើរតួនាទីជាអាជ្ញាធរផែ រួមមានការងារលើកដាក់ ការងាររៀបចំចំណតផែ ការងារគ្រប់គ្រងនាវាចេញ-ចូល និងគ្រប់គ្រងចំណតផែប្រេង/ហ្គាស លើការងារសណ្តាប់ធ្នាប់ឲ្យមានសុវត្ថិភាព និងបរិស្ថានល្អ
- គ្រប់គ្រងនាវាចេញ-ចូល និងប្រមូលស្ថិតិទំនិញឆ្លងកាត់
- ថែរក្សាបបនីយភណ្ឌផែ និងប្រឡាយនាវាចរណ៍នៅតាមចំណតផែទាំងនោះឲ្យមានរបៀបរៀបរយសម្រាប់នាវាធ្វើនាវាចរណ៍ ចងពួរនាវា បោះយុថ្កា ព្រមទាំងផ្ទេរ និងផ្ទុកទំនិញ។

• ***ការងារវាយតម្លៃ***

- ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ ការដាក់ពិន័យ
- វាយតម្លៃរាល់ផលប៉ះពាល់ដែលបណ្តាលឲ្យខូចខាតដល់ចំណតផែ ដែលស្ថិតនៅក្នុងព្រំប្រទល់ផ្ទៃទឹកកំពង់ផែ និងមណ្ឌលផែ ជូនថ្នាក់ដឹកនាំជ្រាប និងមានដំណោះស្រាយ
- រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ ប្រធានស្តីទីនាយកដ្ឋានផែនការ/ទីផ្សារ

• ***ការងារគ្រប់គ្រង***

- ជាសេនាធិការឲ្យអគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ លើការងារផែនការ/ស្ថិតិ ការងារតម្លៃ/ទីផ្សារ ការងារកិច្ចការជំនួយ និងការងារសិក្សាស្រាវជ្រាវ/អភិវឌ្ឍថ្មី
- ផ្តល់ការណែនាំ និងកំណត់ទិសដៅការងាររបស់អង្គភាពក្រោមឱវាទ។

• ***ការងារជំនាញ***

- រៀបចំផែនការអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ រយៈពេលខ្លី មធ្យម និងវែង
- តាមដានការងារអាជីវកម្ម ជាប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំសម្រាប់ ក.ស.ភ
- ចងក្រងទិន្នន័យ និងស្ថិតិរបស់ ក.ស.ភ ដើម្បីធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ
- រៀបចំផែនការយុទ្ធសាស្ត្រទីផ្សាររបស់ ក.ស.ភ ដោយពឹងផ្អែកជាចម្បងទៅលើតម្លៃ គុណភាពសេវាកម្ម ការគ្រប់គ្រង និងបបនីយកណ្ឌផែ
- រៀបចំកិច្ចសន្យា កិច្ចព្រមព្រៀង និង MOU ជាមួយដៃគូអាជីវកម្មរបស់ ក.ស.ភ
- រៀបចំ និងចងក្រងបណ្ណផ្សាយពាណិជ្ជកម្ម(Brochure) និងប្រតិទិន (Calendar)
- ផ្សព្វផ្សាយអំពីតារាងតម្លៃសេវាកម្មរបស់ ក.ស.ភ ជូនអតិថិជន
- បម្រើសេវាកម្ម (Customer Service) ជូនអតិថិជន
- ផលិតវិក្កយបត្រ។

• ***ការងារវាយតម្លៃ***

- ពិនិត្យ និងផ្តល់យោបល់លើគម្រោងសាងសង់ និងការចំណាយផ្សេងៗលើផ្នែកអាជីវកម្មរបស់ ក.ស.ភ ជូនថ្នាក់ដឹកនាំ
- វិភាគអំពីប្រសិទ្ធភាព និងផលប៉ះពាល់នៃគម្រោងអភិវឌ្ឍនីមួយៗរបស់ ក.ស.ភ
- សិក្សាពីបរិយាកាសប្រកួតប្រជែង និងវិនិយោគក្នុងវិស័យដឹកជញ្ជូន វិស័យភ័ស្តុភារ និងវិស័យកំពង់ផែ
- សិក្សា និងវិភាគតម្លៃដឹកជញ្ជូនតាមផ្លូវទឹក ផ្លូវគោក ផ្លូវដែក និងផ្លូវអាកាស
- វិភាគលើផលប៉ះពាល់ ចំណុចខ្លាំង ចំណុចខ្សោយ និងឱកាស ដោយផ្អែកលើមជ្ឈដ្ឋានខាងក្នុង និងខាងក្រៅរបស់អង្គភាព
- តាមដានស្ថានការ និងនិន្នាការអភិវឌ្ឍសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស
- តាមដានស្ថានការនៃការអភិវឌ្ឍ និងការប្រព្រឹត្តទៅរបស់កំពង់ផែក្នុងប្រទេស និងកំពង់ផែ

នានានៅក្នុងប្រទេសជិតខាងក្នុងតំបន់ និងសកលលោក

- សិក្សាអំពីភាពប្រកួតប្រជែងនៃតម្លៃសេវាកម្មរបស់ ក.ស.ភ
- សិក្សាលើគម្រោងស្រាវជ្រាវ និងការអភិវឌ្ឍថ្មីៗរបស់ ក.ស.ភ
- ធ្វើការស្ទង់មតិអំពីការផ្តល់សេវាកម្មរបស់ ក.ស.ភ ដើម្បីទទួលបានការវាយតម្លៃពីអ្នកប្រើប្រាស់លើចំណុចសកម្ម និងចំណុចអសកម្ម
- ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងតួនាទី និងការដាក់ពិន័យ
- រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែ TS៣

• ***ការងារគ្រប់គ្រង***

- ជាសេនាធិការឲ្យអគ្គនាយករងប្រតិបត្តិការ លើការងារប្រតិបត្តិការចំណតផែ TS៣
- ផ្តល់ការណែនាំដល់អង្គភាពក្រោមឱវាទអំពីលំហូរប្រតិបត្តិការ។

• ***ការងារជំនាញ***

- រៀបចំកាលវិភាគ និងចាត់ចែងនាវាចូលចត និងចេញពីផែទៅតាមដងយោងនីមួយៗ
- រៀបចំ និងចាត់ចែងប្លង់របស់កុងតឺន័រទាំងនាំចូល និងនាំចេញ
- ធានាឲ្យការធ្វើប្រតិបត្តិការលើកដាក់លើទីលាន និងនៅស្ពានផែឲ្យស្របតាមស្តង់ដារអន្តរជាតិ និងលក្ខណៈបច្ចេកទេស
- ផ្តល់ការណែនាំដល់កម្មករបម្រើការងារនៅលើចំណត អំពីគោលការណ៍ សន្តិសុខ និងសុវត្ថិភាព
- ធានាឲ្យមានបរិយាកាសការងារល្អជាមួយបុគ្គលិកក្រោមឱវាទ
- រក្សាទំនាក់ទំនងល្អក្នុងចំណោមថ្នាក់ដឹកនាំ និងកម្មករក្រោមឱវាទ
- ជម្រុញការលើកទឹកចិត្តដល់បុគ្គលិកក្រោមឱវាទ
- ជម្រុញគុណភាពការងារតាមរយៈការផ្តល់ការណែនាំ និងការបណ្តុះបណ្តាល
- ធានាឲ្យមានការផ្តល់សេវាកាន់តែល្អ មានប្រសិទ្ធភាព និងផលិតភាពខ្ពស់
- ធ្វើបញ្ជី Check List ផ្នែកប្រតិបត្តិការ
- ល្បាត និងត្រួតពិនិត្យសកម្មភាពប្រតិបត្តិការ ដើម្បីធានាថាបុគ្គលិកផ្នែកប្រតិបត្តិការទាំងអស់ពាក់សម្ភារការពារពលកម្ម(PPE) និងប្រើប្រាស់សម្ភារគ្រឿងចក្របានត្រឹមត្រូវ

- រៀបចំការប្រជុំប្រចាំខែជាមួយបុគ្គលិកក្រោមឱវាទ ដើម្បីពិភាក្សា និងដកពិសោធន៍ការងារកន្លងមក
- ចូលរួមស៊ើបអង្កេតគ្រោះថ្នាក់ការងារដែលបានកើតឡើង
- ត្រួតពិនិត្យមាត់ច្រកចេញ-ចូល។

• *ការងារវាយតម្លៃ*

- បូកសរុបរបាយការណ៍ប្រតិបត្តិការប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំ
- គណនា និងវាយតម្លៃការប្រើប្រាស់ទីលាន ស្ពានផែ និងគ្រឿងចក្រលើកដាក់
- ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់កម្មករ និងវិនិយោគជិតក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងតួនាទី និងការដាក់ពិន័យ។

❖ ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧

• *ការងារគ្រប់គ្រង*

- ជាសេនាធិការឲ្យអគ្គនាយករងប្រតិបត្តិការលើការងារប្រតិបត្តិការចំណតផែកុងតឺន័រLM១៧
- ផ្តល់ការណែនាំដល់អង្គភាពក្រោមឱវាទអំពីលំហូរប្រតិបត្តិការ។

• *ការងារជំនាញ*

- រៀបចំកាលវិភាគនិងចាត់ចែងនាវាចូលចត និងចេញពីផែទៅតាមជងយោងនីមួយៗ
- រៀបចំ និងចាត់ចែងប្លង់របស់កុងតឺន័រទាំងនាំចូល និងនាំចេញ
- ធានាឲ្យការធ្វើប្រតិបត្តិការលើកដាក់លើទីលាន និងនៅស្ពានផែឲ្យស្របតាមស្តង់ដារអន្តរជាតិ និងលក្ខណៈបច្ចេកទេស
- ណែនាំដល់កម្មករបម្រើការងារនៅលើចំណតអំពីគោលការណ៍ សន្តិសុខ និងសុវត្ថិភាព
- ធានាឲ្យមានបរិយាកាសការងារល្អជាមួយបុគ្គលិកក្រោមឱវាទ
- រក្សាទំនាក់ទំនងល្អក្នុងចំណោមថ្នាក់ដឹកនាំ និងកម្មករក្រោមឱវាទ
- ជម្រុញការលើកទឹកចិត្តដល់បុគ្គលិកក្រោមឱវាទ
- ជម្រុញគុណភាពការងារតាមរយៈការផ្តល់ការណែនាំ និងការបណ្តុះបណ្តាល
- ធានាឲ្យមានការផ្តល់សេវាកាន់តែល្អ មានប្រសិទ្ធភាព និងផលិតភាពខ្ពស់
- ធ្វើបញ្ជី Check List ផ្នែកប្រតិបត្តិការ
- ល្បាត និងត្រួតពិនិត្យសកម្មភាពប្រតិបត្តិការ ដើម្បីធានាថាបុគ្គលិកផ្នែកប្រតិបត្តិការទាំងអស់ពាក់សម្ភារការពារពលកម្ម(PPE) និងប្រើប្រាស់សម្ភារគ្រឿងចក្របានត្រឹមត្រូវ

- រៀបចំការប្រជុំប្រចាំខែជាមួយបុគ្គលិកក្រោមឱវាទ ដើម្បីពិភាក្សា និងដកពិសោធន៍ការងារកន្លងមក
- ចូលរួមស៊ើបអង្កេតគ្រោះថ្នាក់ការងារដែលបានកើតឡើង
- ត្រួតពិនិត្យមាត់ច្រកចេញ-ចូល។

• *ការងារវាយតម្លៃ*

- គណនា និងវាយតម្លៃការប្រើប្រាស់ទីលាន ស្ពានផែ និងគ្រឿងចក្រលើកដាក់
- ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់កម្មករ និងវិនិយោគជិតក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ និងការដាក់ពិន័យ
- បូកសរុបរបាយការណ៍ប្រតិបត្តិការប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំ។

### ២.២.២. ហិរញ្ញវត្ថុរបស់កំពង់ផែស្វយ័តភ្នំពេញ

#### ២.២.២.១. ចំណូល

ចំណូលរបស់ ក.ស.ភ ក្នុងឆ្នាំ២០១៧បានមកពីៈ

| | |
|---|---|
| -ចំណូលប្រតិបត្តិការផែ | ១៥.៤៦១.០៥៦ ដុល្លារអាមេរិក |
| -ចំណូលអាជ្ញាធរផែ | ៣.១៦៥.៦១៩ ដុល្លារអាមេរិក |
| -សេវាផ្សេងៗ | ២២៩.៦២១ ដុល្លារអាមេរិក |
| **សរុប** | **១៨.៨៥៦.២៩៦ ដុល្លារអាមេរិក** |

#### ២.២.២.២. ចំណាយ

ក្នុងឆ្នាំ២០១៧ ក.ស.ភ មានមុខសញ្ញាចំណាយមួយចំនួនដូចជាៈ ប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗ ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី-ទឹក និងប្រេងឥន្ធនៈ ការថែទាំនិងជួសជុលសម្ភារៈផ្គត់ផ្គង់ការិយាល័យ បដិសណ្ឋារកិច្ចនិងការកំសាន្ត ការធ្វើដំណើរ រួមទាំងពន្ធផ្សេងៗជាដើម។ល។

#### ២.២.២.៣. ប្រាក់ឧបត្ថម្ភដល់សមាជិកក្រុមប្រឹក្សា និងបុគ្គលិក

ក្រៅពីបៀវត្សសរុបបុគ្គលិក និយោជិតរបស់ ក.ស.ភ អាចទទួលបាននូវប្រាក់ឧបត្ថម្ភបន្ថែមមួយចំនួនទៀតផងដែររួមមានដូចខាងក្រោម[9]ៈ

❖ **ឧបត្ថម្ភបុណ្យទាន**

កម្មករ និយោជិត ក.ស.ភ ទាំងអស់ នឹងអាចទទួលបានប្រាក់ឧបត្ថម្ភដូចខាងក្រោម[10]ៈ

[9] លក្ខន្តិកៈបុគ្គលិក ក.ស.ភ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤

- ទិវានារីអន្តរជាតិ៨មីនា៖ កម្មករ និយោជិតស្ត្រី ទទួលបានប្រាក់ឧបត្ថម្ភចំនួន ២០០.០០០ រៀល/ម្នាក់។
- បុណ្យចូលឆ្នាំប្រពៃណីខ្មែរ៖ ក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋ កម្មករ និយោជិតម្នាក់ៗ ទទួលបានប្រាក់ឧបត្ថម្ភចំនួន ១៥% នៃប្រាក់បៀវត្សសរុបខែមីនារបស់សាមីខ្លួន។
- បុណ្យភ្ជុំបិណ្ឌ៖ កម្មករ និយោជិតម្នាក់ៗ ទទួលបានប្រាក់ឧបត្ថម្ភចំនួន ១៥% នៃប្រាក់បៀវត្សសរុបខែសីហា របស់សាមីខ្លួន។

❖ **ប្រាក់លើសម៉ោង ប្រាក់ឧបត្ថម្ភថ្ងៃឈប់សម្រាក និងថ្ងៃបុណ្យ**

ចំពោះប្រាក់កម្រៃនេះត្រូវបានផ្តល់ជូនតែ កម្មករ និយោជិត ដែរបានចាត់តាំងឲ្យបំពេញការងារស្នូល នៅពេលយប់ ឬលើសម៉ោងកំណត់ប៉ុណ្ណោះ ហើយចំពោះកម្មករ និយោជិតដែរធ្វើការតាមវេនមិនត្រូវបានផ្តល់ជូនទេ។ ដោយឡែកថ្នាក់គ្រប់គ្រង ចាប់ពីអនុប្រធានអង្គភាពឡើង ប្រាក់លើសម៉ោងថ្ងៃធ្វើការធម្មតាមិនត្រូវបានទទួលទេ។

រយៈពេលបំពេញការងារលើសម៉ោងក្រោម៤ម៉ោងគិតកន្លះថ្ងៃ បើលើស៤ម៉ោងគិតមួយថ្ងៃ

- សម្រាប់ថ្ងៃធ្វើការធម្មតា ២០.០០០រៀល/ថ្ងៃ/នាក់
- សម្រាប់ថ្ងៃឈប់សម្រាក និងថ្ងៃបុណ្យ ៣០.០០០រៀល/ថ្ងៃ/នាក់

❖ **ឧបត្ថម្ភពេលសម្រាលកូន និងករណីមរណភាព**

- ឧបត្ថម្ភកម្មករ និយោជិត ជាស្ត្រី ពេលសម្រាលកូនចំនួន ៨០០.០០០រៀល
- ឧបត្ថម្ភភរិយា កម្មករ និយោជិត ពេលសម្រាលកូនចំនួន ៥០០.០០០រៀល ក្នុងករណីភរិយាមិនមែនជានិយោជិត ក.ស.ភ
- ឧបត្ថម្ភករណីមរណភាពរបស់ស្វាមី-ភរិយា-កូនក្នុងបន្ទុកចំនួន ៥០០.០០០រៀល
- ឧបត្ថម្ភគ្រួសារសពករណីមរណភាពរបស់កម្មករ និយោជិត ក.ស.ភ ៤.០០០.០០០រៀល

## ២.៣. ផែនការអនាគតសម្រាប់ឆ្នាំ ២០១៨

ខាងក្រោមគឺជាគម្រោងអនាគតដែលមានតម្លៃវិនិយោគលើសពី ១០០.០០០ ដុល្លារអាមេរិក ដែលនឹងត្រូវវិនិយោគក្នុងរយៈពេល ១ឆ្នាំ ទៅ ៥ឆ្នាំខាងមុខ[11]។

❖ **គម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី២ របស់ចំណតផែកុងតឺន័រ LM១៧**

ចន្លោះពីឆ្នាំ ២០១២ ដល់ឆ្នាំ២០១៧ ចំនួនកុងតឺន័រដែលឆ្លងកាត់ជាមធ្យមកើនឡើងប្រហែល១២,៥០% រៀងរាល់ឆ្នាំ។ ដោយសារតែកុងតឺន័រដែលឆ្លងកាត់បច្ចុប្បន្ននៅ LM១៧ មាន

[10] លក្ខន្តិកៈបុគ្គលិក ក.ស.ភ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤, ក្នុងឧបសម្ព័ន្ធ៕

[11] របាយការណ៍ប្រចាំឆ្នាំ២០១៧ របស់កំពង់ផែស្វយ័តភ្នំពេញ

ចំនួន ១៨៩.៨០៥TEUs ក្នុងឆ្នាំ២០១៧ ក.ស.ភ ព្យាករណ៍ថាចំនួនកុងតឺន័រនឹងបន្តកើនឡើងដល់ ២០០.០០០TEUs ក្នុងឆ្នាំ២០១៨។ ដើម្បីទទួលបានកំណើននេះ ក.ស.ភ ត្រូវធ្វើការពង្រីកបបនីយភណ្ឌផែ និងបរិក្ខារបន្ថែមទៀត។

• *រយៈពេលអនុវត្តគម្រោង (២០១៦-២០១៨)*

• *ទីតាំង និងទំហំនៃគម្រោង*

- នៅភាគខាងកើតចំណតផែកុងតឺន័រ LM១៧
- ចំនួន ៥ ហិកតា

• *ប្រភពហិរញ្ញវត្ថុ*

- មូលធនទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង
- មូលនិធិបម្រុងរបស់ ក.ស.ភ

• *ថវិកាត្រូវចំណាយ*

- ពង្រីកទីលានកុងតឺន័រ បរិមាត្រផ្ទៃសរុប (១៧.៨៥០ម៉ែត្រការ៉េ) ដោយចាក់ថ្មមិចៈ ៩៩៩.៨០០ ដុល្លារអាមេរិក
- សាងសង់ផ្លូវសម្រាប់រថស្ទូច RTG ចំនួន ៤ ខ្សែ (ប្រវែង ៥៩៤ ម៉ែត្រ) ៖ ៨៦៩.១៣០ ដុល្លារអាមេរិក
- សាងសង់ផ្លូវសម្រាប់រថយន្តកុងតឺន័រ ចំនួន ២ ខ្សែ (ប្រវែង ២៧២ ម៉ែត្រ) ៖ ៣៩៤.៣៩០ ដុល្លារអាមេរិក
- បំពាក់រថស្ទូច RTG ចំនួន ៤ គ្រឿង៖ ៥.៨០០.០០០ ដុល្លារអាមេរិក
- សាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹក និងអគ្គិសនី៖ ៧៥៩.០០០ ដុល្លារអាមេរិក
- សាងសង់ទំនប់ (៣០០ម x ៣១ម)៖ ១.៧៩៨.៨៥៨ ដុល្លារអាមេរិក
- សាងសង់របង (៧៥០ម)៖ ៧៩.៨២៨ ដុល្លារអាមេរិក

❖ **គម្រោងបំពាក់កុងរ៉ូយ៉័រនៅចំណតផែកុងតឺន័រ LM១៧**

ក្រៅពីលើកដាក់ទំនិញជាកុងតឺន័រនៅចំណតផែកុងតឺន័រ LM១៧ ក.ស.ភ ពុំទាន់មានឧបករណ៍សម្រាប់ផ្ទុក និងផ្ទេរទំនិញរាយទេ។ ដូច្នេះ ក.ស.ភ មានគម្រោងក្នុងការបំពាក់កុងរ៉ូយ៉័រដើម្បីឆ្លើយតបទៅនឹងការកើនឡើង នៃតម្រូវការសេវាកម្មលើកដាក់ទំនិញរាយនៅចំណតផែកុងតឺ-ន័រ LM១៧។

• *រយៈពេលអនុវត្តគម្រោង (២០១៨)*

• *ទីតាំងនៃគម្រោង*

- នៅភាគខាងកើតចំណតផែកុងតឺន័រ LM១៧

• *ប្រភពហិរញ្ញវត្ថុ*

- មូលធនទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង
- មូលនិធិបម្រុងរបស់ ក.ស.ភ

• *ថវិកាត្រូវចំណាយ*

- បំពាក់កុងរ៉ូយ័រចំនួន ៤ ខ្សែរ ១៦០.០០០ ដុល្លារអាមេរិក

❖ **គម្រោងបំពាក់កុងរ៉ូយ័រនៅចំណតផែពហុបំណង TS៣**

មុនការស្ថាបនាចំណតផែកុងតឺន័រ LM១៧ ក្នុងដំណាក់កាលទី១ ចំណតផែពហុបំណងTS៣ គឺជាផែចម្បងសម្រាប់ការលើកដាក់ទំនិញកុងតឺន័រ និងទំនិញរាយ។ ដោយសារការពង្រីកទីលានកុងតឺន័រ មានកម្រិតដើម្បីទទួលចរាចរណ៍កុងតឺន័រ ដែលកើនឡើងជារៀងរាល់ឆ្នាំ ក.ស.ភ បានវិនិយោគលើការអភិវឌ្ឍចំណតផែកុងតឺន័រLM១៧។ នៅខែធ្នូ ឆ្នាំ២០១៤ ចំណតផែពហុបំណងTS៣ បានប្រើប្រាស់សម្រាប់ទទួលទំនិញរាយ និងអ្នកដំណើរជាចម្បង។ ដូចនេះហើយ ក.ស.ភ មានគម្រោងបំពាក់កុងរ៉ូយ័រដើម្បីជម្រុញប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាពក្នុងការទទួលទំនិញរាយ។

• *រយៈពេលអនុវត្តគម្រោង (២០១៨)*

• *ទីតាំងនៃគម្រោង*

- នៅលើស្ពានផែដែលមានស្រាប់នៅចំណតផែពហុបំណង TS៣

• *ប្រភពហិរញ្ញវត្ថុ*

- មូលធនទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង
- មូលនិធិបម្រុងរបស់ ក.ស.ភ

• *ថវិកាត្រូវចំណាយ*

- បំពាក់កុងរ៉ូយ័រចំនួន ៤ ខ្សែរ ១៦០.០០០ ដុល្លារអាមេរិក

## ២.៤. ទិសដៅការងារឆ្នាំ ២០១៨

- អភិវឌ្ឍធនធានមនុស្ស
- ពង្រីក និងអភិវឌ្ឍចំណតផែរណបតាមដងទន្លេ
- បង្កើតតំបន់ភ័ស្តុភារកម្ម និងឃ្លាំងទំនើប
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចំណតផែកុងតឺន័រ LM១៧ ជំហានទី២
- បន្តបូមស្តារ និងថែទាំប្រឡាយនាវាចរណ៍
- បំពាក់គ្រឿងចក្រលើកដាក់បន្ថែម ដើម្បីធានាប្រសិទ្ធភាពប្រតិបត្តិការលើកដាក់

- ចាប់ផ្តើមគម្រោងបង្កើតរោងចក្រកែច្នៃស្រូវ អង្ករ និងឃ្លាំងត្រជាក់នៅចំណាតផែកុងតឺន័រ LM១៧ ក្រោមទម្រង់ភាពជាដៃគូ រវាងរដ្ឋ និងឯកជន
- បន្តសហការជាមួយប្រទេសវៀតណាម ដើម្បីបូមស្តារផ្លូវនាវាចរណ៍ពីចំណាតផែកុងតឺន័រ LM១៧ ដល់ព្រំប្រទល់ កម្ពុជា-វៀតណាម (ភ្នមសំណារ) និងពីភ្នមសំណារ ដល់កំពង់ផែកាន់ថឺ នៃប្រទេសវៀតណាម។

# ជំពូកទី៣
# ការអនុវត្តកិច្ចការរដ្ឋបាល
# កំពង់ផែស្វយ័តភ្នំពេញ

# ជំពូកទី៣
# ការអនុវត្តកិច្ចការរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ

## ៣.១. កិច្ចប្រជុំ

កិច្ចប្រជុំ គឺជាការជួបប្រជុំគ្នាដែលមានគោលបំណងយ៉ាងច្បាស់លាស់ ដោយមានការផ្លាស់ប្តូរយោបល់ និងការពិគ្រោះពិភាក្សា ជាមធ្យោបាយដ៏ចម្បងមួយ ក្នុងការសម្រេចនូវគោលបំណងទាំងនោះ។

ជាទូទៅ កិច្ចប្រជុំចែកចេញជាកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ ដែលអាចរៀបចំឡើងដោយសាធារណៈ ឬដោយសម្ងាត់ ដែលអាស្រ័យទៅនឹងគោលបំណង ឬការតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

កិច្ចប្រជុំសាមញ្ញ គឺជាកិច្ចប្រជុំដែលត្រូវបានរៀបចំឡើងជាទៀងទាត់ ទៅតាមពេលវេលាកំណត់ជាក់លាក់ណាមួយ។

កិច្ចប្រជុំវិសាមញ្ញ គឺជាកិច្ចប្រជុំដែលត្រូវបានរៀបចំជាបន្ទាន់ដោយពុំអាចរង់ចាំការប្រជុំសាមញ្ញបានដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេស។

នៅក្នុង ក.ស.ភ មានកិច្ចប្រជុំជាផ្លូវការចំនួន០២(ពីរ) គឺៈ

- កិច្ចប្រជុំក្រុមប្រឹក្សាភិបាល
- កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក

### ៣.១.១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលរួមមានកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ ។ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវចូលរួមប្រជុំសាមញ្ញយ៉ាងតិច ៣ (បី)ខែម្តង។ ហើយអាចប្រជុំជាវិសាមញ្ញរាល់ពេលណា ដែរមានតម្រូវការចាំបាច់ និងជាផលប្រយោជន៍របស់ ក.ស.ភ តាមការផ្តួចផ្តើមរបស់ប្រធាន ឬ តាមការស្នើសុំរបស់សមាជិកចំនួន ៤ រូប ឬ របស់អគ្គនាយក ឬ ប្រធានអគ្គនាយក[12]។

ក្រុមប្រឹក្សាភិបាល ធ្វើការពិភាក្សាសម្រេចលើបញ្ហាដែលបានចុះក្នុងរបៀបវារៈ ហើយរបៀបវារៈនោះត្រូវជូនដំណឹងយ៉ាងតិច ១០ (ដប់)ថ្ងៃ ជាមុនដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋ។

ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចយកជាការបាន លុះត្រាតែមានសមាជិកភាគច្រើនចូលរួម ២/៣ (ពីរភាគបី) ឡើងទៅ។ សមាជិកក្រុមប្រឹក្សាភិបាលដែលអវត្តមាន មិនអាចឲ្យគេចូល

[12]លក្ខន្តិកៈកំពង់ផែស្វយ័តភ្នំពេញ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤,មាត្រា២១

ជំនួសបានឡើយ។ ករណីប្រធានអវត្តមាន អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ត្រូវដឹកនាំដោយសមាជិកណាម្នាក់ដែលជ្រើសតាំងក្នុងចំណោមសមាជិកដែលមានវ័យចំណាស់ជាងគេ ដើម្បីដឹកនាំការប្រជុំ។

- **ការប្រព្រឹត្តទៅនៃកិច្ចប្រជុំ**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបានលុះណាតែមានវត្តមានសមាជិកយ៉ាងតិចពាក់កណ្តាល។ ក្នុងករណីការប្រជុំលើកទី១ ពុំគ្រប់កូរ៉ុម នោះការកោះអញ្ជើញលើកទី២ ត្រូវបញ្ជូនក្នុងរយៈពេល ១៥ ថ្ងៃបន្ទាប់។ ការពិភាក្សាពេលនេះអាចប្រព្រឹត្តទៅបាន ពុំចាំបាច់តម្រូវកូរ៉ុមទេ ដោយពិភាក្សាតែលើរបៀបវារៈ ដែលបានចុះជាមួយការអញ្ជើញនៅលើកទី១ ព្រមទាំងត្រូវមានបញ្ជីវត្តមាន ដែលមានចុះហត្ថលេខារបស់សមាជិកក្រុមប្រឹក្សាភិបាលដែលបានចូលរួម។ ការសម្រេចត្រូវអនុម័តយកតាមមតិភាគច្រើនរបស់សមាជិកចូលរួម ដោយការលើកដៃ។ ក្នុងករណីមានសម្លេងស្មើគ្នា នោះសម្លេងរបស់ប្រធាន ចាត់ទុកជាសម្លេងឧត្តមានុភាព។

- **កិច្ចការក្រោយពេលប្រជុំ**

កិច្ចពិភាក្សារបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាទុកក្នុងសៀវភៅពិសេសមួយ ដោយរក្សាទុកនៅទីចាត់ការរបស់ ក.ស.ភ ហើយត្រូវចុះហត្ថលេខាដោយប្រធាន និងលេខាធិការនៃអង្គប្រជុំ។ ដែលកំណត់ហេតុប្រជុំត្រូវបញ្ជូនក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់)ថ្ងៃក្រោយពីការប្រជុំ ដោយត្រូវផ្ញើជូនទៅគ្រប់សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋ ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កំណត់ហេតុនោះ ត្រូវឆ្លុះបញ្ចាំងនូវខ្លឹមសារនៃការពិភាក្សាដេញដោល។ ករណីមានសំណូមពរ ឬការតវ៉ាពីសមាជិកណាម្នាក់ លេខាធិការត្រូវកត់ត្រាចូលក្នុងកំណត់ហេតុ ហើយត្រូវចុះក្នុងរបៀបវារៈសម្រាប់ការប្រជុំលើកក្រោយ[13]។

### ៣.១.២. កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក

កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក គឺជាកិច្ចប្រជុំសាមញ្ញដែលគេរៀបចំឡើង ១ឆ្នាំម្តង។ កិច្ចប្រជុំនេះត្រូវធ្វើឡើងនៅសាលប្រជុំជាន់ទី៣នៃអាគាររដ្ឋបាល ទីស្នាក់ការកណ្តាល(ចំណតផែTS៣) ដែលស្ថិតនៅអាគារលេខ ៦៤៧ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ[14]។

- **សេចក្តីសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក**

សេចក្តីសម្រេចរបស់មហាសន្និបាតភាគហ៊ុនិករួមមាន ប្រជុំសម្រេចលើជ្រើសរើសសមាជិក

[13] លក្ខន្តិកៈកំពង់ផែស្វយ័តភ្នំពេញ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៩,មាត្រា២២

[14] របាយការណ៍ប្រចាំឆ្នាំ២០១៧ របស់កំពង់ផែស្វយ័តភ្នំពេញ

ក្រុមប្រឹក្សាភិបាល សមាជិកតំណាងភាគហ៊ុនិកឯករាជ្យ សមាជិកតំណាងភាគហ៊ុនិកមិនឯករាជ្យ ផែនការអភិវឌ្ឍរយៈពេលវែងរបស់ ក.ស.ភ ការបង្កើនដើមទុនរបស់ ក.ស.ភ ការបន្ថយដើមទុនរបស់ ក.ស.ភ និងការរំលាយ ក.ស.ភ ជាដើម។

## ៣.២. លិខិតរដ្ឋបាលរបស់ ក.ស.ភ

លិខិតរដ្ឋបាលរបស់ ក.ស.ភ រួមមាន សេចក្តីជូនដំណឹង លិខិតបង្គាប់ការ លិខិតឧទ្ទេសនាម លិខិតអញ្ជើញ លិខិតបញ្ជាបេសកកម្ម របាយការណ៍ និងកំណត់ហេតុ ជាដើម។

- **សេចក្តីជូនដំណឹង** គឺជាលិខិតដែល ក.ស.ភ រៀបចំឡើងដើម្បីធ្វើការទំនាក់ទំនងជាមួយបុគ្គល ឬ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលមានខ្លឹមសារជាការឆ្លើយបំភ្លឺចំពោះបញ្ហា ឬការឆ្លើយតបចំពោះសំណើរ ឬជាការជូនដំណឹងឲ្យសាធារណៈជន បានដឹងនូវពត៌មានទាំងឡាយដែល ក.ស.ភ ត្រូវផ្សព្វផ្សាយ។

- **លិខិតបង្គាប់ការ** គឺជាលិខិតដែល ក.ស.ភ រៀបចំឡើងសម្រាប់អ្វីដែលពាក់ព័ន្ធទៅនឹងស្ថានភាពមុខតំណែងណាមួយ ឬការតែងតាំងមន្ត្រីណាម្នាក់ក្នុងរយៈពេលខ្លី បណ្តោះអាសន្នដោយមានការកំណត់។

- **លិខិតឧទ្ទេសនាម** គឺជាលិខិតដែល ក.ស.ភ រៀបចំឡើងសម្រាប់ជាការបង្ហាញនូវនាមរបស់បុគ្គលណាម្នាក់ ឬច្រើននាក់ឲ្យបុគ្គលិកបានស្គាល់។

- **លិខិតអញ្ជើញ** គឺជាលិខិតដែល ក.ស.ភ រៀបចំឡើងដើម្បីធ្វើការអញ្ជើញបុគ្គល ឬតំណាងក្រសួង-ស្ថាប័ន ឲ្យចូលរួមក្នុងសកម្មភាពរបស់ ក.ស.ភ ចំពោះកិច្ចការដែរពាក់ព័ន្ធទៅនឹងបុគ្គល ឬស្ថាប័ននោះ ដោយមានបញ្ជាក់ឈ្មោះ ឋានៈ (អ្នកដែរត្រូវអញ្ជើញ) ទីកន្លែងប្រជុំ កាលបរិច្ឆេទ ឬរបៀបវារៈប្រជុំ។

- **លិខិតបញ្ជាបេសកកម្ម** គឺជាលិខិតដែល ក.ស.ភ រៀបចំឡើងដើម្បីធ្វើការចាត់តាំងមន្ត្រីបុគ្គលិក ក.ស.ភ ឲ្យចូលរួមសកម្មភាពនានាដែលនៅខាងក្រៅស្ថាប័ន។

- **របាយការណ៍** គឺជាសេចក្តីរាយការណ៍អំពីសកម្មភាព ដំណើរការ និងលទ្ធផលការងាររបស់ ក.ស.ភ ឬបុគ្គលណាម្នាក់ ឬក្រុមណាមួយដែលរដ្ឋបាល ក.ស.ភ បានបំពេញ ឬបានចាត់តាំងឲ្យទៅបំពេញបេសកកម្ម ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធ។

- **កំណត់ហេតុ** គឺជាកត់ត្រាស្រង់យកមតិយោបល់ សេចក្តីសម្រេច និងការឯកភាពលើសកម្មភាពដែលត្រូវអនុវត្តពីគ្រប់សមាជិកអង្គប្រជុំ និងការសម្រេចរបស់អង្គប្រជុំ ដើម្បីរក្សាទុកជាសក្ខីភាពនៅពេលដែលមានតម្រូវការ។

## ៣.៣. ចំណុចខ្លាំង និង ចំណុចខ្សោយរបស់កំពង់ផែស្វយ័តភ្នំពេញ

### ៣.៣.១. ចំណុចខ្លាំង

- ការបម្រើសេវាកម្មប្រតិបត្តិការផែរបស់ ក.ស.ភ ជូនអតិថិជនមានភាពឆាប់រហ័ស

- ការផ្សព្វផ្សាយស្តីពីការផ្តល់សេវាកម្មរបស់ ក.ស.ភ ជូនអតិថិជនមានភាពទូលំទូលាយ

- ក.ស.ភ មានការយកចិត្តទុកដាក់ខ្ពស់ទៅលើសុខភាពបុគ្គលិក ដោយរៀបចំនូវបរិស្ថាន និងទីកន្លែងការងារប្រកបដោយផាសុខភាព និងគ្មានផលរំខានពីខាងក្រៅ

- ក.ស.ភ បានផ្តោតជាសំខាន់លើក្រមសីលធម៌របស់បុគ្គលិក ។ ក្នុងនាមជាបុគ្គលិករបស់កំពង់ផែត្រូវតែជាបុគ្គលដែលមានក្រមសីលធម៌ល្អចេះធ្វើឲ្យអ្នកដទៃគោរព និងកោតស្ញប់ស្ញែង

- ក.ស.ភ មាននីតិវិធីក្នុងការជ្រើសរើសបុគ្គលិក ឲ្យបម្រើការងារប្រកបដោយតម្លាភាព ម្យ៉ាងទៀតកំពង់ផែក៏មាននីតិវិធី និងគោលការណ៍ផ្សេងៗសម្រាប់ឲ្យបុគ្គលិកដែលកំពុងបម្រើការងារអនុវត្តតាមដែលបង្កភាពងាយស្រួលក្នុងការគ្រប់គ្រង និងមានភាពយុត្តិធម៌សម្រាប់បុគ្គលិកទាំងអស់

- ក.ស.ភ មានការលើកទឹកចិត្តចំពោះបុគ្គលិក ដោយមានជាការផ្តល់នូវប្រាក់ឧបត្ថម្ភនៅក្នុងឱកាសបុណ្យទាន និងបុណ្យជាតិ ហើយថែមទាំងផ្តល់ប្រាក់ឧបត្ថម្ភចំពោះគ្រួសាររបស់បុគ្គលិក នៅពេលមានការសម្រាលកូន និងករណីមរណភាព

- បុគ្គលិកមានភាពសាមគ្គី និងចេះជួយគ្នាទៅវិញទៅមកក្នុងការសម្រេចការងារ។ ម្យ៉ាងវិញទៀត បុគ្គលិកតាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោមមានទំនួលខុសត្រូវខ្ពស់ គោរពពេលវេលា ហើយចេះបង្កើននូវភាពស្និតស្នាលប្រកបដោយការគោរព

- បុគ្គលិកនៅ ក.ស.ភ ទាំងអស់បានបែងចែកមុខងារ និងតួនាទីបានច្បាស់លាស់។

### ៣.៣.២. ចំណុចខ្សោយ

- សមត្ថភាពនៅមានកម្រិតចំពោះការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា

- ការប្រើបច្ចេកទេសក្នុងការទំនាក់ទំនងពីនាយកដ្ឋានមួយ ទៅនាយកដ្ឋានមួយទៀតនៅមានកម្រិត។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ឆ្លងកាត់តាមការបកស្រាយ និងសិក្សាស្រាវជ្រាវទៅលើប្រធានបទ ″ការគ្រប់គ្រងរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ″ រួចមក នាងខ្ញុំបានយល់ដឹងជាច្រើនពីអ្វីដែលពាក់ព័ន្ធទៅនឹងស្ថាប័នដូចជាសញ្ញាណទូទៅនៃសហគ្រាសសាធារណៈ ទំនាក់ទំនងរវាងសហគ្រាសនិងរដ្ឋ ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលរបស់កំពង់ផែស្វយ័តភ្នំពេញ តួនាទី និងភារកិច្ចរបស់ថ្នាក់ដឹកនាំស្ថាប័ន។ល។ ម្យ៉ាងវិញទៀត ធ្វើឲ្យខ្ញុំបានយល់ដឹងកាន់តែច្បាស់អំពីសារៈសំខាន់នៃការគ្រប់គ្រងរដ្ឋបាល ព្រោះការគ្រប់គ្រងរដ្ឋបាលគឺជាចំណុចស្នូលមួយយ៉ាងសំខាន់ក្នុងការបង្កើន និងជម្រុញប្រសិទ្ធភាពការងាររបស់ស្ថាប័ន ឬអង្គភាពមួយឲ្យមានដំណើរការប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យការងារ។

សរុបសេចក្ដីមក បន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងចុះកម្មសិក្សាដោយផ្ទាល់នៅ ក.ស.ភ នាងខ្ញុំអាចធ្វើការសន្និដ្ឋានជារួមបានថា ការគ្រប់គ្រងរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ មានប្រសិទ្ធភាពខ្ពស់។ ដោយ ក.ស.ភ មានបទបញ្ញត្តិជាតិដែលពាក់ព័ន្ធទៅនឹងការងាររដ្ឋបាល និងមានមូលដ្ឋានផ្អែកលើទ្រឹស្ដីរដ្ឋបាលច្បាស់លាស់ ដែលធ្វើឲ្យផលិតកម្មអាជីវកម្មរបស់ ក.ស.ភ មានការរីកចម្រើនជាបន្តបន្ទាប់។ បើទោះបីជា ក.ស.ភ មានចំណុចខ្លាំងជាច្រើន ដូចដែលបានរៀបរាប់ខាងលើក៏ដោយ ក៏ប៉ុន្តែ ក.ស.ភ ក៏នូវមានចំណុចខ្សោយមួយចំនួនដូចជា (១) សមត្ថភាពនូវមានកម្រិតចំពោះការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា(E-government and Digital-document)។ (២)ការប្រើបច្ចេកទេសក្នុងការទំនាក់ទំនងពីនាយកដ្ឋានមួយទៅនាយកដ្ឋានមួយទៀតនៅមានកម្រិត។ ដែលគួរតែពិនិត្យមើលនិងកែលម្អនូវចំណុចទាំងនោះ ដើម្បីជម្រុញឲ្យដំណើរការគ្រប់គ្រងរដ្ឋបាលកាន់តែមានប្រសិទ្ធភាពខ្ពស់ និងបង្កើននូវសក្ដានុពលរបស់ខ្លួនបន្ថែមទៀត។

# អនុសាសន៍

# អនុសាសន៍

ឆ្លងកាត់តាមការសិក្សា ស្រាវជ្រាវ និងសន្និដ្ឋានពីប្រធានបទ ″ការគ្រប់គ្រងរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ″ រួចមក នាងខ្ញុំសង្កេតឃើញថា ក.ស.ភ គឺជាស្ថាប័នមួយដែលមានដំណើរការគ្រប់គ្រងល្អប្រសើរ ជាពិសេសគឺការបម្រើសេវាកម្មប្រតិបត្តិការផែជូនអតិថិជនមានភាពឆាប់រហ័សដែលជាការទាក់ទាញ និងការបង្កើននូវទំនុកចិត្តរបស់អតិថិជន។ យោងទៅតាមសេចក្តីសន្និដ្ឋានខាងលើ នាងខ្ញុំពិនិត្យឃើញថា ការគ្រប់គ្រងរដ្ឋបាលកំពង់ផែមាននូវចំណុចខ្វះខាតបន្តិចបន្តួចដែលគួរគប្បីពិនិត្យមើលបន្ថែម។ ក្នុងនាមខ្ញុំជានិស្សិត ដែលបានចុះកម្មសិក្សានៅកំពង់ផែស្វយ័តភ្នំពេញ សូមអនុញ្ញាតផ្តល់ជាមតិយោបល់ខ្លះទៅលើចំណុចខ្វះខាតដែលពាក់ព័ន្ធនឹងប្រធានបទនេះក្នុងគោលដៅពង្រឹង និងបង្កើននូវប្រសិទ្ធភាពការងារឲ្យកាន់តែល្អប្រសើរថែមទៀត។

នាងខ្ញុំបានស្វែងរកនូវអនុសាសន៍បន្តិចបន្តួចទៅលើ ដំណើរការគ្រប់គ្រងរដ្ឋបាលដូចជាៈ

- ក.ស.ភ គួរតែពង្រឹងនូវសមត្ថភាពរបស់បុគ្គលិកឲ្យកាន់តែខ្លាំងបន្ថែមទៀត ទៅលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា
- ចំពោះការប្រើបច្ចេកទេសក្នុងការទំនាក់ទំនងពីនាយកដ្ឋានមួយ ទៅនាយកដ្ឋានមួយទៀតគួរតែជម្រុញឲ្យមានការប្រើប្រព័ន្ធបច្ចេកវិទ្យាឲ្យបានច្រើន ដើម្បីសម្រួលដល់ការងារមួយចំនួនដែលមានភាពចាំបាច់
- គួរបង្កើតជាវគ្គសិក្សាបណ្តុះបណ្តាលខ្លី ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា (E-government and Digital-document)។

# គន្ថនិទ្ទេស


- ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែរប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ ១៩៩៦
- អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ(ក.ស.ភ)
- លក្ខន្តិកៈកំពង់ផែស្វយ័តភ្នំពេញ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤
- លក្ខន្តិកៈបុគ្គលិកនៃក.ស.ភ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៤
- សៀវភៅស្តីពី "នីតិវិធីរដ្ឋបាលទូទៅ" រៀបរៀងដោយសាស្ត្រាចារ្យបណ្ឌិត សាយ បូរី ,បោះពុម្ពលើកទី៣ (២០០៦)
- របាយការណ៍ប្រចាំឆ្នាំ ២០១៦ និង ២០១៧ របស់កំពង់ផែស្វយ័តភ្នំពេញ
- http:// www.ppap.com.kh (ថ្ងៃចូលមើលទី ០៩ ខែ មេសា ឆ្នាំ ២០១៨)

# ឧបសម្ព័ន្ធ ១

# លិខិតឧទ្ទេសនាម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ំពង់ផែស្វយ័តភ្នំពេញ**

...០៨៣/១៨...ក. ស. ភ.

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព. ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨

## លិខិតឧទ្ទេសនាម

**យោង** : លិខិតលេខ ៣៩៩ សកនវស ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨ របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**កំពង់ផែស្វយ័តភ្នំពេញ**

**សូមឧទ្ទេសនាម** : កញ្ញា **កែ ហួយ** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី១១ ក្រុម P4C1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**ដើម្បី** : ចុះកម្មសិក្សា និងស្វែងយល់ ពីការងារមួយចំនួនដែលទាក់ទង នឹងប្រធានបទស្តីពី " ការគ្រប់គ្រងរដ្ឋបាលកំពង់ផែស្វយ័តភ្នំពេញ " នៅនាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស នៃកំពង់ផែស្វយ័តភ្នំពេញ។

**កាលបរិច្ឆេទ** : ការចុះកម្មសិក្សានេះ ត្រូវបានអនុញ្ញាតឲ្យរយៈពេល ០២ខែ ដោយគិតចាប់ពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨។

អាស្រ័យហេតុនេះ សូមលោក លោកស្រី ដែលពាក់ព័ន្ធនឹងការងារនេះ មេត្តាជួយសហការ និង សម្រួលដល់និស្សិតខាងលើ ដើម្បីបំពេញភារកិច្ចឲ្យបានល្អប្រសើរ។

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**ប្រធានអគ្គនាយក**

**ហ៊ី-បាវី**

# ឧបសម្ព័ន្ធ ២
# រចនាសម្ព័ន្ធបុគ្គលិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

កំពង់ផែស្វយ័តភ្នំពេញ
Phnom Penh Autonomous Port
លេខ:...........ក.ស.ក/PPAP

# រចនាសម្ព័ន្ធគ្រប់គ្រង ក.ស.ភ




សំគាល់:
- ប្រធានការិយាល័យ, ប្រធានសេវាដ្ឋាន ជាជំនួយការអោយប្រធាននាយកដ្ឋាន (គ្មានអនុប្រធាននាយកដ្ឋាន)
- ប្រធានការិយាល័យ = ប្រធានសេវាដ្ឋាន = ប្រធានអង្គភាពលទ្ធកម្ម
- ប្រធានអង្គភាព = អនុប្រធានការិយាល័យ = អនុប្រធានសេវាដ្ឋាន

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ.....ឆ្នាំ ២០១៥
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
ប្រធានអគ្គនាយក

ទីតាំងការិយាល័យកណ្តាល: អគារលេខ ៦៤៩ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទ/ទូរសារ (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh
Head Office: # 649, Preah Sisowat, Sangkat Sras Chork, Khan Doun Penh, Phnom Penh
Fax/Phone: (855) 23 427 802. Email: ppapmpwt@online.com.kh / info@ppap.com.kh

# ឧបសម្ព័ន្ធ ៣

# ច្បាប់ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់

## ស្តីពី

# លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

១៧៩៦

រដ្ឋសភា
លេខ ១៥៣៨
ថ្ងៃទី ១៧ ៩ ៩៦ ម៉ោង ១១
បញ្ជូនទៅ

# ព្រះរាជក្រម

នស / រកម / ០៦៩៦ / ០៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង របស់ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២២ ឆ្នាំ១៩៩៦ នាសម័យប្រជុំ លើកទី៦ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

**មាត្រា ៤៨.-**

អាណាព្យាបាលពិសេស ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការដែលបាននិងកំពុងបំពេញការងារយ៉ាងតិច៥ឆ្នាំ ។ អាណាព្យាបាលពិសេសត្រូវបានតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ អាណាព្យាបាលពិសេស ត្រូវសុំមតិណែនាំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុនពេលចូលរួមមហាសន្និបាតក្រុមហ៊ុនចំរុះ ។

## ជំពូកទី ៤

### អវសានប្បញ្ញត្តិ

**មាត្រា ៤៩.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៦ នាសម័យប្រជុំ
រដ្ឋសភាលើកទី ៦ នីតិកាលទី ១ ។

ភ្នំពេញ,ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រធានរដ្ឋសភាស្ដីទី

លយ ស៊ីមឈាង

# ឧបសម្ព័ន្ធ ៤

# អនុក្រឹត្យស្តីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ ក.ស.ភ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៥១...អនក្រ.បក

ចុះលេខ...120...
ថ្ងៃទី..21....ខែ.7....ឆ្នាំ1998..
ម៉ោង...

# អនុក្រឹត្យ

## ស្តីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ ក.ស.ភ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត_១០៩៤_៨៣_ចុះថ្ងៃទី២៤_១០_៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ ជស.រកត.០៨៩៧_១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម នស_រកម_ ០១_៩៦_០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦_១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦៩៦/០៣ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

..........................ល.ប.
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី.........ខែ.........ឆ្នាំ២០០៥
ត.ប. អភិបាលរាជធានីភ្នំពេញ
ជ. នាយខុទ្ទកាល័យ

សំរេច

ជំពូក១

បទបញ្ញត្តិទូទៅ

មាត្រា១ ត្រូវបានបង្កើតសហគ្រាសសាធារណៈដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋឈ្មោះ " កំពង់ផែស្វយ័តក្រុងភ្នំពេញ " សរសេរកាត់ ( ក.ស.ត ) ដែលស្ថិតក្រោម អាណាព្យាបាលរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រោមអាណាព្យាបាល ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ក.ស.ត មានទីស្នាក់ការនៅ ក្រុងភ្នំពេញ
- ក.ស.ត គឺជានីតិបុគ្គលមានស្វ័យភាពផ្នែកបច្ចេកទេសផ្នែករដ្ឋបាលនិងផ្នែកហិរញ្ញវត្ថុ ។
- ក.ស.ត ត្រូវស្ថិតក្រោមឥទ្ធិពលបទបញ្ញត្តិនៃអនុក្រឹត្យនេះ ហើយនឹងគោរពតាមបទបញ្ញត្តិនៃព្រះរាជក្រម លេខ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ព្រមទាំងបទបញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម ។

មាត្រា២ ក.ស.ត មានភារកិច្ចធ្វើអាជីវកម្ម _សេវាកម្មមូលដ្ឋានលើការងារ :

- កណ្ដាលការកិច្ច និងផ្ដល់ភស្តុភារដល់នាវា
- លើកដាក់ផ្ទេរ _ ផ្ទុក និងដឹកជញ្ជូនទំនិញ
- ការងារថែរក្សា ស្តុកទំនិញ ឃ្លាំង ទីលាន
- ការងារអភិវឌ្ឍ និងស្តារហេដ្ឋារចនាសម្ព័ន្ធ ក.ស.ត ដែលមាន ដែលត្រូវពង្រីក

មាត្រា៣ ក.ស.ត មានភារកិច្ច :

- ទទួលខុសត្រូវ និងចាត់ចែងលើការងារការពារសុវត្ថិភាព សន្តិសុខ សណ្ដាប់ធ្នាប់ក្នុងតំបន់គ្រប់គ្រង ។
- ប្រកាន់គោលការណ៍ និងរបៀបកិច្ចការ ដូចគ្នានឹងអាជីវករ ។
- គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាពឱ្យមានប្រសិទ្ធភាព និងមានការរីកចំរើន ។
- ក្នុងឋានៈជាស្ថាប័នសាធារណៈ ក,ស,ក ទទួលពីរដ្ឋនូវអំណាច និងភារកិច្ចទាំងឡាយដើម្បីបំពេញ បេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។

មាត្រា៤ លើកលែងបទបញ្ញត្តិផ្ទុយពីនេះ ក,ស,ក ត្រូវបង់ពន្ធអាករស្របតាមច្បាប់និងបទបញ្ជា ជាធរមាន ។

មាត្រា៥ ដើមទុនដំបូងនៃ ក.ស.ត ត្រូវកំណត់ដោយបញ្ជីតុល្យការដំបូង ដែលបានទទួលការ [illegible] ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន ។

[illegible]

ភ្នំពេញ, ថ្ងៃទី.........ខែ.........ឆ្នាំ២០០៤

ត.ប. [illegible]

ជ. [illegible]

ពេលដែលអនុក្រឹត្យនេះចូលជាធរមាន ក.ស.ត ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ ជំនួសរដ្ឋ លើទ្រព្យសម្បត្តិទាំងអស់ ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

មាត្រា៦ បុគ្គលិករបស់ ក.ស.ត ត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែក ដែលសំរេចដោយ ក្រុមប្រឹក្សាភិបាល ដោយផ្អែកលើព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។
ចាប់ពីពេលដែលលក្ខន្តិកៈដោយឡែកនេះ ចូលជាធរមាន បុគ្គលិករបស់ ក.ស.ត មិនស្ថិតក្នុងក្របខ័ណ្ឌ របស់រដ្ឋតទៅទៀតទេ ។

## ជំពូក២

## ការដឹកនាំ និងការគ្រប់គ្រង

មាត្រា៧ ក.ស.ត ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

- ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | ១ រូប ជាប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប ជាសមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប ជាសមាជិក |
| - តំណាងរាជធានីក្រុងភ្នំពេញ | ១ រូប ជាសមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | ១ រូប ជាសមាជិក |
| - តំណាងនិយោជិករបស់ ក.ស.ត | ១ រូប ជាសមាជិកស្វ័យប្រវត្តិ |
| - អគ្គនាយក ក.ស.ត | ១ រូប ជាសមាជិក |

មាត្រា៨ សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីសកម្ម ធ្លាប់បានបំរើការងារ យ៉ាងតិច០៥ (ប្រាំ) ឆ្នាំ ឬជាឯកជនជន ដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រដែល មានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មព្រហ្មទណ្ឌកំរិតធ្ងន់ ពីតុលាការឡើយ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយ អនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលា និងអាចបន្តទៀតបាន ដោយអនុក្រឹត្យតាមសំណើ របស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឱ្យ ។
- តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិត ក.ស.ត ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី.........ខែ.........ឆ្នាំ២០០៥
ត.ប. អភិបាលរាជធានីភ្នំពេញ
ជ. នាយខុទ្ទកាល័យ

មាត្រា៩ ក្រុមប្រឹក្សាភិបាលមានសិទ្ធពេញលេញ ដើម្បីសំរេចក្នុងនាមនៃ ក.ស.ត ក្នុងការរៀបចំលិខិតស្នាមរាល់ឯកសារផ្សេងៗ ទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាស ស្របតាមច្បាប់ជាធរមាន មានជាអាទិ៍ :

១- ផ្តល់ការយល់ព្រមលើគំរោងសហគ្រាស ដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀបរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការ ដើម្បីកែសំរួលឱ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើតុល្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសកម្មភាពរបស់ ក.ស.ត ។

៤- សំរេច តាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ប្រមទាំងលក្ខន្តិកៈនិងតាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់បុគ្គលិកដោយ អនុលោមតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងអនុសញ្ញាដែល ក.ស.ត ជាភាគីស្របតាមលក្ខខ័ណ្ឌ និងបែបបទដូចមានគ្រោង ក្នុងបទបញ្ជាជាធរមាន ស្តីពីកិច្ចសន្យានិងអនុសញ្ញា ដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេចបង្កើត បើក ឬបិទ ការិយាល័យ និងទីភ្នាក់ងារគ្រប់ទីកន្លែងរបស់ ក.ស.ត តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- កំណត់លើតំលៃឈ្នួលពាក់ព័ន្ធនិងការធ្វើអាជីវកម្ម សេវាកម្ម លើកំពង់ផែ ។

មាត្រា១០ ក្រុមប្រឹក្សាភិបាល បើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាសតាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើនៃសមាជិកដែលមានបួននាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

ទោះជាយ៉ាងណាក៏ដោយក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច ១ដងក្នុងរយៈពេល ៣ខែ ។

ករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់ ដែលមានវ័យចំណាស់ជាងគេ ដើម្បីដឹកនាំការប្រជុំ ។

ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយ ដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។ របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋ ឱ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបានលុះណាតែមានវត្តមានសមាជិក យ៉ាងតិចពាក់កណ្តាល ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងវិញ លើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះ ពុំចាំបាច់ទាមទារកូរ៉ុមទេ ។
- សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការ អនុម័តដោយសំឡេងភាគច្រើន នៃសមាជិកអង្គប្រជុំ ។ ប្រសិនជាការបែកសំឡេង មានចំនួនស្មើគ្នា សំឡេងរបស់ប្រធាន ជាសំឡេងសម្រេច

ត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី........ខែ.........ឆ្នាំ២០០៤

ត.ប. អភិបាលរាជធានីភ្នំពេញ

ជ. នាយខុទ្ទកាល័យ

មាត្រា១១ សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅ អាណាព្យាបាល ទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងទៅមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដ៏ទៃទៀត ដែលមានចែងក្នុងមាត្រា២៤ នៃអនុក្រឹត្យនេះ ក្នុងរយៈ១៥ថ្ងៃយ៉ាងយូរ ចាប់រាប់ពីថ្ងៃប្រជុំ។ កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាននៃអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ដែលមានវត្តមានក្នុងកិច្ចប្រជុំពេលមុននោះ ។

មាត្រា១២ អគ្គនាយកមានភារកិច្ច ជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ ក.ស.ត និងត្រូវបានតែងតាំងសំរាប់ អាណត្តិ ៣ ឆ្នាំ ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងអាណាព្យាបាល ។

មាត្រា១៣ ក្រុមប្រឹក្សាភិបាល ត្រូវប្រគល់ជូនអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះអគ្គនាយកត្រូវ ៖

១- រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ចាត់ចែងអនុវត្តរាល់សេចក្តីសំរេច របស់ក្រុមប្រឹក្សាភិបាល ។ តាមតំណាក់កាលនីមួយៗ អគ្គនាយកត្រូវរាយការណ៍ជូន ក្រុមប្រឹក្សាភិបាល អំពីសកម្មភាពរបស់ ក.ស.ត ។

២- ទទួលដឹកនាំ ក.ស.ត លើផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម និងហិរញ្ញវត្ថុ ។

៣- តំណាងឱ្យ ក.ស.ត ចំពោះមុខតតិយជនទាំងឡាយ ក្នុងការបំពេញលិខិតស្នាមស៊ីវិលរដ្ឋបាល ឬលិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤- មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតដំណែង ឬបញ្ឈប់ការងារ និងមានសិទ្ធិបញ្ជា ត្រួតត្រា បណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ ក.ស.ត ដោយអនុវត្តតាម ( លក្ខន្តិកៈបុគ្គលិក ) ឬច្បាប់ជាធរមាន និងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥- មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រី ដែលនៅក្រោមឱវាទស្របតាមល័ក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

តំណាងឱ្យក.ស.ត ចំពោះមុខតុលាការ និងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ ក្នុងករណីចោទប្រកាន់ឥវ៉ាការពារក្តីឱ្យ ក.ស.ត និងការប្តឹងជំទាស់ផ្សេងៗ ។

មាត្រា១៤ លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់អគ្គនាយកត្រូវកំណត់ដោយក្រសួងអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី........ខែ.........ឆ្នាំ២០០៥
ត.ប. អភិបាលរាជធានីភ្នំពេញ
ជ. នាយខុទ្ទកាល័យ

មាត្រា១៥ ការចុះ និងការអនុវត្តកិច្ចសន្យាដោយ ក.ស.គ ត្រូវគោរពតាមបែបបទ និងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា១៦ ក.ស.គ កាន់កាប់គណនេយ្យរបស់ខ្លួន ឱ្យបានសមស្របតាមបទបញ្ញាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលគេទទួលស្គាល់ជាទូទៅ ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្ដើមពីថ្ងៃ០១ ខែមករា ហើយបញ្ចប់នៅថ្ងៃ៣១ ខែធ្នូ នៃឆ្នាំដដែល ។

តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃ៣០ ខែមិនា នៃឆ្នាំបន្ទាប់ឆ្នាំបិទការិយបរិច្ឆេទ ឈរលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ ដែលមានមុខងារជាស្នងការគណនី ។

តុល្យការនិងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនី ត្រូវដាក់សុំការយល់ព្រម ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃ ដែលក្រុមប្រឹក្សាភិបាល បានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះ ត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ផងដែរ ដើម្បីសុំមតិទៅតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃច្បាប់ ស្ដីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា១៧ -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុសំរាប់អាណត្តិបីការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-ប្រាក់បំណាច់សំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយ ក្នុងជំពូកបន្ទុកអាជីវកម្មរបស់ ក.ស.គ ។

- ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំ នៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.គ ។
- បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។
- ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ ប្រធានក្រុមប្រឹក្សាភិបាល ។

លេខ:..........................ស.ជ.
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី.........ខែ.........ឆ្នាំ២០០៥
ត.ប. អភិបាលរាជធានីភ្នំពេញ
ជ. នាយខុទ្ទកាល័យ

មាត្រា១៨ រៀងរាល់ឆ្នាំ មុនថ្ងៃ ៣០ ខែកញ្ញា ក្រុមប្រឹក្សាភិបាល ត្រូវផ្តល់ការយល់ព្រមលើគំរោងសហគ្រាសប្រចាំឆ្នាំ តាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័ត ពីរដ្ឋមន្ត្រីក្រសួង សាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

គំរោងប្រចាំឆ្នាំត្រូវបញ្ជាក់នូវ ៖

១_ កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុង សំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២_ ថវិកាសំរាប់ដំណើរការនៃសហគ្រាស ។

៣_ តម្លៃឈ្នួលលើកដាក់ប្រគល់ ដឹកជញ្ជូន និងតំលៃឈ្នួលសេវានាវាចរណ៍_ពន្ធផែ_ស្តុកឃ្លាំង ។

៤_ លក្ខណវិនិច្ឆ័យ សំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់ ក.ស.ត ។

មាត្រា១៩ _ ធនធាននៃ ក.ស.ត ជាអាទិមាន ៖

- ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឱ្យ ( តុល្យការដំបូង នៅពេលបង្កើត )
- ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទ បានមកពីសកម្មភាពរបស់សហគ្រាស ។
- ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ ក.ស.ត ។
- ប្រាក់ខ្ចីបុល និងប្រាក់អំណោយផ្សេងៗ ។

មាត្រា២០ ចំណាយនៃ ក.ស.ត រួមមាន ៖

- ចំណាយប្រក្រតីសំរាប់ដំណើរការ
- ចំណាយវិនិយោគ
- សងបំណុល
- ចំណាយផ្សេងៗ

មាត្រា២១ ក.ស.ត អាចមានគណនីចរន្ត ក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់តំរូវការរបស់ខ្លួន ។

មាត្រា២២ ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេច ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រាក់ចំណេញដែល ក.ស.ត ទទួលបាន ក្រោយពីការទូទាត់ស្របតាមវិធានការគណនេយ្យ ដែលគេទទួលស្គាល់ ជាទូទៅត្រូវបញ្ចូលទៅក្នុងគណនីមូលនិធិបំរុងហិរញ្ញវត្ថុរបស់ ក.ស.ត ។

មាត្រា២៣ ការខ្ចីបុលរយៈពេលមធ្យម ឬវែង សំរាប់ប្រើប្រាស់ក្នុងការវិនិយោគ ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុន ។

លេខ:.......................ល.ប.

បានឃើញថាច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី........ខែ.........ឆ្នាំ២០០៥

ត.ប. អភិបាលរាជធានីភ្នំពេញ

ប. នាយខុទ្ទកាល័យ

## ជំពូក៤

## ការទំនាក់ទំនងជាមួយរដ្ឋ

**មាត្រា២៤** : រយៈពេល ១៥ ថ្ងៃ យ៉ាងយូរបំផុត ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ក.ស.ត ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងសហគ្រាស( ដូចមានចែងក្នុងមាត្រា១៨ )
- របាយការណ៍ស្តីពីសកម្មភាព_តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ ក.ស.ត
- របាយការណ៍របស់ស្នងការគណនី ។

**មាត្រា២៥** ត្រូវបានដាក់ឱ្យនៅអម ក.ស.ត នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំងដោយ អនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈ តែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្ម ដោយអនុលោមតាមបទបញ្ញត្តិ នៃមាត្រាទី ២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស_ រកម_ ០៦៩៦ / ០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃ សហគ្រាសសាធារណៈ ។

**មាត្រា២៦** ក.ស.ត មានសិទ្ធិផ្អាកការងារ ចំពោះអតិថិជន ឬឯកជនណាមួយ ដែលពុំព្រមបង់ប្រាក់ ថ្លៃឈ្នួលផ្សេងៗ តាមកិច្ចសន្យា និងកិច្ចព្រមព្រៀង ។

## ជំពូក៥

## អវសានបញ្ញត្តិ

**មាត្រា២៧** បទបញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រតិភូរាជរដ្ឋាភិបាលក្រុងភ្នំពេញ អគ្គនាយកកំពង់ផែក្រុងភ្នំពេញ ត្រូវអនុវត្តនូវអនុក្រឹត្យនេះ ។

......................ហ.ប.

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី.........ខែ.........ឆ្នាំ២០០៥

ក.ប. អភិបាលរាជធានីភ្នំពេញ

ជ. នាយខុទ្ទកាល័យ

មាត្រា២៨ អនុក្រឹត្យនេះ ចូលជាបទបញ្ញត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

អ៊ុង ហួត ហ៊ុន សែន

បានជំរាបជូន
ឯកឧត្តមនាយករដ្ឋមន្ត្រីទី១
សម្តេចនាយករដ្ឋមន្ត្រីទី២

ជ. រដ្ឋមន្ត្រីក្រសួង
សាធារណការនិងដឹកជញ្ជូន
រដ្ឋលេខាធិការ

ត្រាំ អ៊ីវតឹក

ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួង
សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

លេខ:...1153..........ល.ប.
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី...24.ខែ...03..ឆ្នាំ២០០៤

សុខ ស៊ុយ



កន្លែងទទួល
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រះបរមរាជវាំង
- ខុទ្ទកាល័យឯកឧត្តមនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- ដូចមាត្រា ២៧
- ឯកសារ-កាលប្បវត្តិ

៨

# ឧបសម្ព័ន្ធ ៥
# លក្ខន្តិកៈកំពង់ផែស្វយ័តភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងសាធារណការ និង ដឹកជញ្ជូន

# លក្ខន្តិកៈ

# កំពង់ផែស្វយ័តភ្នំពេញ(ក.ស.ភ)

កំពង់ផែស្វយ័តភ្នំពេញ

PHNOM PENH AUTONOMOUS PORT

# លក្ខន្តិកៈ

# កំពង់ផែស្វយ័តភ្នំពេញ

ក្រសួងពាណិជ្ជកម្ម
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
តំកល់ទុកលេខ: 1278 / 2004 ពណ.ចបព
ថ្ងៃទី 03-11-2015 ម៉ោង 9:10
មន្ត្រីនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ប្រការ ១._ ទម្រង់គតិយុត្ត និងឈ្មោះ

**អនុលោមតាម ៖**

– ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ព្រមទាំងបទប្បញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម

– អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ស្ដីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ

– អនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩ ស្ដីពីការបង្កើតមណ្ឌលអាជីវកម្មផែភ្នំពេញ

ត្រូវបានបង្កើតសហគ្រាសសាធារណៈ ដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋ ឈ្មោះ "**កំពង់ផែស្វយ័តភ្នំពេញ**" សរសេរជាអក្សរកាត់ "**ក.ស.ភ**" ជាភាសាអង់គ្លេស "Phnom Penh Autonomous Port" សរសេរជាអក្សរកាត់ "PPAP"។

### ប្រការ ២._ ទីចាត់ការ

ក.ស.ភ មានទីចាត់ការស្ថិតនៅអគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការផ្លាស់ប្ដូរទីចាត់ការទៅកាន់កន្លែងផ្សេងៗ ត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាល និងមានការបញ្ជាក់យល់ព្រមពីរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក.ស.ភ អាចមានការិយាល័យ សៅដ្ឋាន សាខា ទីភ្នាក់ងារ នៅទីតាំងផ្សេងទៀតដែល ក.ស.ភ យល់ថាមានការចាំបាច់។

### ប្រការ ៣._ គោលដៅ និងភារកិច្ច

ក.ស.ភ មានកម្មវត្ថុសំដៅទទួលរ៉ាប់រងក្នុងការគ្រប់គ្រង ថែទាំ និងធ្វើអាជីវកម្មសេវាកំពង់ផែ ព្រមទាំងអនិស្សរវត្ថុនៃកំពង់ផែនេះ ដើម្បីប្រតិបត្តិការពង្រីក និងអភិវឌ្ឍសម្រាប់តម្រូវការនៃពាណិជ្ជកម្ម ឧស្សាហកម្ម

ប្រការទាំងឡាយនៃលក្ខន្តិកៈនេះ នៅពេលណាក៏បាន តែវិសោធនកម្មនេះ មិនត្រូវប៉ះពាល់ដល់សិទ្ធិអ្នកដែលមានផលប្រយោជន៍ពាក់ព័ន្ធជាមួយ ក.ស.ភ ឡើយ។

រាល់សកម្មភាព ឬ កិច្ចសន្យាណាដែល ក.ស.ភ បានទទួលការអនុញ្ញាតឱ្យអនុវត្តមុនវិសោធនកម្ម ពុំមានបាត់បង់សុពលភាពឡើយ។

**ប្រការ ៤៩._ សុពលភាពនៃលក្ខន្តិកៈ**

លក្ខន្តិកៈនេះ មានសុពលភាពអនុវត្តចាប់ពីថ្ងៃដែលបានទទួលការយល់ព្រមពីក្រសួងអាណាព្យាបាល និងបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មរួច។ លក្ខន្តិកៈរបស់ ក.ស.ភ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ ត្រូវបាននិរាករណ៍ និងត្រូវបានជំនួសដោយលក្ខន្តិកៈថ្មីនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**[illegible] អូន ព័ន្ធមុនីរ័ត្ន**

បានយកសេចក្តីគោរពជម្រាបជូន
ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង
ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខា
**ប្រធានក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តភ្នំពេញ**

**ហ៊ី ឬាវី**

ក្រសួងពាណិជ្ជកម្ម
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
លេខ 1298/2004
ថ្ងៃ 03-11-2015

# ឧបសម្ព័ន្ធ ៦

# របាយការណ៍ប្រចាំឆ្នាំ ២០១៧

# របស់ ក.ស.ភ

## ៦- លាភការ ឬប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

*ក- ឈ្មោះ តំណែងអភិបាល និងបុគ្គលិកជាន់ខ្ពស់ និងប្រាក់បំណាច់ ឬលាភការ ដែលទទួលបានខ្ពស់បំផុត ៖*

(ឯកតា៖ពាន់រៀល)

| ល.រ | ឈ្មោះអភិបាល និងបុគ្គលិកជាន់ខ្ពស់ | មុខតំណែងក្នុងក.ស.ភ. | ប្រាក់បៀវត្សរ៍ និងលាភការ មធ្យមប្រចាំខែ | ចំនួនសរុប ប្រាក់បៀវត្សរ៍ និងលាភការ |
|---|---|---|---|---|
| | | | ឆ្នាំ២០១៧ | |
| ១ | ហ៊ី បាវី | ប្រធានអគ្គនាយក | ២១.១៩១ | ២៥៤.៣០២ |
| ២ | ណែម ធីម | ទីប្រឹក្សា | ៧.២៦៨ | ៨៧.២២០ |
| ៣ | គីម សែន | ទីប្រឹក្សា | ៥.២៥៥ | ៦៣.០៦៨ |
| ៤ | គោ នី | អគ្គនាយករង | ៦.២៤៩ | ៧៤.៩៩៨ |
| ៥ | កុយ ប៊ុនធន | អគ្គនាយករង | ៨.០០២ | ៩៦.០២៩ |
| ៦ | ហៀក ភិរុណ | អគ្គនាយករង | ៧.២៨៤ | ៨៧.៤១៤ |
| ៧ | ហ៊ី ផានិន | អគ្គនាយករង | ៦.៩៦២ | ៨៣.៥៥៥ |
| ៨ | គង់ ចាន់នី | ប្រធានលេខាធិការដ្ឋាន | ៧.៤៩១ | ៨៩.៨៩៥ |
| ៩ | កែវ សុផាណ្ណារ៉ា | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | ៥.៩៨១ | ៧១.៧៧៥ |
| ១០ | ជួន សុខេម | ប្រធាននាយកដ្ឋានរដ្ឋបាល | ១៣.៩៤៦ | ១៦៧.៣៥៥ |
| ១១ | គង់ សុផា | ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស | ៦.០០១ | ៧២.០១៥ |
| ១២ | ឈាវ វណ្ណធា | ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ | ៦.៩៤៦ | ៨៣.៣៥៥ |
| ១៣ | ជី វិចិត្រ | ប្រធាននាយកដ្ឋានវិស្វកម្ម | ៥.៩៧១ | ៧១.៦៥៥ |
| ១៤ | ជៀប វីរ៉ាយ៉ា | ប្រធាននាយកដ្ឋានជលធារសាស្ត្រ | ៥.៩៥៦ | ៧១.៤៧៥ |
| ១៥ | គុល សុខុម | ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ | ៥.៩៩៦ | ៧១.៩៥៩ |
| ១៦ | សយ សេរីសុវឌ្ឍនៈ | ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែគោកស្រុក | ៥.៩៤៦ | ៧១.៣៥៥ |
| ១៧ | ហ៊ុន សុខាល័យ | ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ | ៤.៨២១ | ៥៧.៨៦១ |
| ១៨ | យឹម ជឿន | ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែ | ៦.១៦១ | ៧៣.៩៣៧ |
| សរុប | | | ១៣៧.៤២៧ | ១.៦៤៩.២២៣ |

**សម្គាល់៖*

*- លោកស្រី ហ៊ី ផានិន ត្រូវបានតែងតាំងជាអគ្គនាយករង ចាប់ពីខែមីនា ឆ្នាំ២០១៧ និងលោក គោ នី ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានចាប់ពីខែកុម្ភៈ ឆ្នាំ២០១៧ ។*

*- លោក គោ នី ត្រូវបានតែងតាំងជាអគ្គនាយករង និងលោក ហ៊ុន សុខាល័យ ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានចាប់ពីខែ វិច្ឆិកា ឆ្នាំ២០១៧ ។*

*ខ- ចំនួនប្រាក់បំណាច់ ឬលាភការសរុប ដែលបើកឱ្យអភិបាលមិនប្រតិបត្តិ*

(ឯកតា៖ ពាន់រៀល)

| ល.រ | ឈ្មោះអភិបាលមិនប្រតិបត្តិ | មុខតំណែងក្នុង ក.ស.ភ | ប្រាក់បៀវត្សរ៍ / ប្រាក់បំណាច់ |
|---|---|---|---|
| | | | ឆ្នាំ ២០១៧ |
| ១ | ឯកឧត្តម សូន រចនា | អភិបាល | ៩៦.០០០ |
| ២ | ឯកឧត្តម កែន សម្បត្តិ | អភិបាល | ៩៦.០០០ |
| ៣ | ឯកឧត្តម ប៉ែន សុវិជាតិ | អភិបាល | ៩៦.០០០ |
| ៤ | លោក ហ្គី អានវ៉ានិថ | អភិបាលឯករាជ្យ | ៩៦.០០០ |
| ៥ | លោក ឌិត សុចល | អភិបាលមិនប្រតិបត្តិ | ៩៦.០០០ |
| ៦ | លោក ម៉ម រិទ្ធី | មន្ត្រីត្រួតពិនិត្យរដ្ឋ | ៩៦.០០០ |
| សរុប | | | **៥៧៦.០០០** |

***សម្គាល់៖ លោក ហ្គី អានវ៉ានិថ និង លោក ឌិត សុចល ត្រូវបានតែងតាំងដោយអនុក្រឹត្យលេខ ៦៧៦ អនក្រ.តត ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦***

*គ- ចំនួនប្រាក់បៀវត្សរ៍សរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់*

(ឯកតា៖ពាន់រៀល)

| ល.រ | ឈ្មោះអភិបាល និង បុគ្គលិកជាន់ខ្ពស់ | មុខតំណែងក្នុងក.ស.ភ. | ប្រាក់បំណាច់ និងលាភការសរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខ |
|---|---|---|---|
| ១ | ឯកឧត្តម ហ៊ី បាវី | អភិបាល | ២៥៤.៥៥៦ |
| ២ | ឯកឧត្តម សូន រចនា | អភិបាល | ៩៦.០០០ |
| ៣ | ឯកឧត្តម កែន សម្បត្តិ | អភិបាល | ៩៦.០០០ |
| ៤ | ឯកឧត្តម ប៉ែន សុវិជាតិ | អភិបាល | ៩៦.០០០ |
| ៥ | លោក ហ្គី អានវ៉ានិថ | អភិបាលឯករាជ្យ | ៩៦.០០០ |
| ៦ | លោក ឌិត សុចល | អភិបាលមិនប្រតិបត្តិ | ៩៦.០០០ |
| ៧ | លោក ម៉ម រិទ្ធី | មន្ត្រីត្រួតពិនិត្យរដ្ឋ | ៩៦.០០០ |
| ៨ | ឯកឧត្តម ណែម ធីម | ទីប្រឹក្សា | ៥៨.៩១០ |
| ៩ | លោកជំទាវ គីម សែន | ទីប្រឹក្សា | ០ |
| ១០ | លោក តា នី | អគ្គនាយករង | ៥៨.៩៤០ |
| ១១ | លោក កុយ ប៊ុនធន | អគ្គនាយករង | ៩៦.១២៥ |

| | | | |
|---|---|---|---|
| ១២ | លោក ហៀក ភិរុណ | អគ្គនាយករង | ៩៦.១២៥ |
| ១៣ | លោកស្រី ហ៊ី ផានិន | អគ្គនាយករង | ៩៦.១២៥ |
| ១៤ | លោក គង់ ចាន់នី | ប្រធានលេខាធិការដ្ឋាន | ៨៩.៩៨៤ |
| ១៥ | លោក កែវ សុផាណ្ណារ៉ា | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | ៧១.៨៨៦ |
| ១៦ | លោកស្រី ជូន សុខេម | ប្រធាននាយកដ្ឋានរដ្ឋបាល | ១៦៧.៥២២ |
| ១៧ | លោក គង់ សុផា | ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស | ៧២.០៨៧ |
| ១៨ | កញ្ញា ឈាវ វណ្ណធា | ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ | ៨៣.៨៣៨ |
| ១៩ | លោក ជី វិចិត្រ | ប្រធាននាយកដ្ឋានវិស្វកម្ម | ៧១.៧២៦ |
| ២០ | លោក ជៀប វីរ៉ាយ៉ា | ប្រធាននាយកដ្ឋានជលធារាសាស្ត្រ | ៧១.៥៨៦ |
| ២១ | លោក គុល សុខុម | ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ | ៧២.០៣០ |
| ២២ | លោក សយ សេរីសុវណ្ណនៈ | ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែក្នុងស្រុក | ៧១.៤២៦ |
| ២៣ | លោក ហ៊ិន សុខាល័យ | ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ | ៧១.៥២០ |
| ២៤ | លោក យឹម ជឿន | ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ | ៧៤.០១០ |
| សរុប | | | **១.៥៧៦.៩២២** |

*សម្គាល់៖*

*- លោកជំទាវ គីម សែន ចូលនិវត្តន៍ចាប់ពីខែកក្កដា ឆ្នាំ២០១៧*

*- ឯកឧត្តម ណៃម ធីម ចូលនិវត្តន៍ចាប់ពីខែតុលា ឆ្នាំ ២០១៧*

*- ការប៉ាន់ស្មានប្រាក់បៀវត្សរ៍របស់បុគ្គលិកជាន់ខ្ពស់សម្រាប់រយៈពេល ០១ឆ្នាំ ទៅមុខ ផ្អែកលើកំណើន ប្រាក់TEUs ។*

*ឃ- ការបង្កើនប្រាក់បំណាច់ ឬលាភការសេរុបក្នុងចំនួនច្រើន ដល់អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត*

ប្រាក់បៀវត្សរ៍របស់ក្រុមប្រឹក្សាភិបាល មានការកើនឡើង លុះត្រាតែមានការស្នើសុំតាមរយៈការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។ ទន្ទឹមនេះ ប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិកជាន់ខ្ពស់ អាចនឹងមានការកើនឡើង ឬថយចុះ អាស្រ័យទៅតាមចំនួនកុងតឺន័រ TEUs ដែលឆ្លងកាត់កំពង់ផែ ប្រចាំខែ។

## ៧. ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

*ក- គោលការណ៍នៃក្រមសីលធម៌*

ក្រមសីលធម៌នេះ ជាក្រមប្រតិបត្តិ ដែលត្រូវអនុវត្តចំពោះក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ក.។

រាល់ការបំពានលើក្រមសីលធម៌នេះ អាចនឹងត្រូវទទួលទណ្ឌកម្មនានាទៅតាមនីតិវិធី ដែលប្រតិបត្តិដោយក្រុមប្រឹក្សាភិបាល។ គោលការណ៍ និងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមសីលធម៌នេះ ត្រូវបានតាក់តែងឡើង ដោយអនុលោមតាមច្បាប់ជាធរមាន ដើម្បីឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ក. គោរពប្រតិបត្តិតាម។ ក្រមសីលធម៌នេះ មិនត្រូវបានប្រើ ដើម្បីជំនួសការដោះស្រាយវិវាទតាមផ្លូវតុលាការនោះទេ។

យន្តការតាមដាន និងរក្សាតុល្យភាព (Checks and Balances) ដែលមានក្នុងក្រមសីលធម៌នេះ ត្រូវបានរៀបចំឡើង ដើម្បីធានាតុល្យភាពក្នុងការគ្រប់គ្រង និងការគោរពកាតព្វកិច្ចកំណត់ដោយច្បាប់ ព្រមទាំងការពារក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ពីការចោទប្រកាន់មិនត្រឹមត្រូវ ឬគ្មានហេតុផលណា មួយ។ ការចោទប្រកាន់បែបនេះ នឹងអាចមានផលប៉ះពាល់ដល់អាជីវកម្មរបស់ ក. ស. ក. ឬប៉ះពាល់ផលប្រយោជន៍ដល់បុគ្គលណាម្នាក់។ សមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ក. ស. ក. អះអាង និងប្តេជ្ញាថានឹងគោរពតាមគោលការណ៍ និងកាតព្វកិច្ច ដូចមានចែងនៅក្នុងក្រមសីលធម៌នេះ។

- និយមន័យ

| | | |
|---|---|---|
| ក្រុមប្រឹក្សាភិបាល | ៖ | សំដៅដល់ក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តភ្នំពេញ។ |
| អភិបាល | ៖ | សំដៅដល់សមាជិកនៃក្រុមប្រឹក្សាភិបាល ហើយអាចជាអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ ឬ អភិបាលឯករាជ្យ។ |
| អភិបាលឯករាជ្យ | ៖ | សំដៅដល់សមាជិកឯករាជ្យ ដែលបំពេញតាមលក្ខខណ្ឌនៃជំពូកទី៥ នៃប្រកាសស្តីពី អភិបាលកិច្ចអាជីវកម្ម សម្រាប់សហគ្រាសសាធារណៈ បោះផ្សាយលក់មូលបត្រជាសាធារណៈ និងដែលជាទូទៅសំដៅដល់អភិបាល ដែលអាចមានភារកិច្ចដោយមិនមានទំនាស់ផលប្រយោជន៍ ដែលកើតឡើងពាក់ព័ន្ធជាមួយ ក.ស.ក.។ |
| អភិបាលប្រតិបត្តិ | ៖ | សំដៅដល់អភិបាលដែលកាន់តំណែងជាបុគ្គលិកជាន់ខ្ពស់នៅក្នុង ក.ស.ក.។ |
| អភិបាលមិនប្រតិបត្តិ | ៖ | សំដៅដល់អភិបាលដែលមិនអនុវត្តនូវប្រតិបត្តិការប្រចាំថ្ងៃក្នុង ក. ស. ក. ឬក៏ជាអភិបាលមិនប្រតិបត្តិជាតំណាងភាគហ៊ុនិកឯកជននិងសាធារណៈ។ |
| បុគ្គលិកជាន់ខ្ពស់ | ៖ | សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែងចាប់ពីប្រធាននាយកដ្ឋាន រហូតដល់អគ្គនាយក រួមទាំងលេខាធិការរបស់ ក. ស. ក. និងប្រធានសវនកម្មផ្ទៃក្នុង និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។ |

### ក.២. ការវិភាគចំណូលតាមផ្នែក

ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ប្រៀបធៀបនឹងដំណាច់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | |
|---|---|---|---|---|
| | ពាន់រៀល | ប្រៀបធៀបនឹងចំណូលសរុប | ពាន់រៀល | ប្រៀបធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ក្រោមដងយោង(Stevedoring) | ៣១.២៩៨.០៦២ | ៤១,០៣% | ២៧.១៩៥.៧៨០ | ៤១,១៦% |
| ចំណូលលើកដាក់លើទីលាន(LOLO) | ២៦.៦៨៩.៣៥១ | ៣៤,៩៩% | ២១.៦៩៩.៨៧៤ | ៣២,៨៥% |
| ចំណូលពីកិច្ចការផែ | ១២.៨០៤.៩២៩ | ១៦,៧៩% | ១១.៦៤៩.៥៣៨ | ១៧,៦៣% |
| ចំណូលពីច្រកទ្វារ | ២.៧១១.៤៨១ | ៣,៥៥% | ២.២២៩.៥១១ | ៣,៣៧% |
| ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ | ១.៧២៣.៨៦៥ | ២,២៦% | ១.៩៣៩.១៩០ | ២,៩៤% |
| ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ | ១៥៥.៦៣១ | ០,២០% | ១.២៩១.៨១៧ | ១,៩៦% |
| ចំណូលពីការវាស់ស្ទង់ | ៧៧៣.១៨៦ | ១,០១% | ៣៧.៨១៤ | ០,០៦% |
| ចំណូលពីការដឹកជញ្ជូន | ២.៩៤៥ | ០,០០% | ៦.៥២១ | ០,០១% |
| ចំណូលពីថ្លៃឈ្នួលថ្លឹងកុងតឺន័រ | ១១៣.៧៨២ | ០,១៥% | ១៥.៩៦៥ | ០,០២% |
| ចំណូលពីសេវាកម្មជូសជុលនិងថែទាំកុងតឺន័រ | ៨៨៥ | ០,០០% | - | ០,០០% |
| សរុប: | **៧៦.២៧៣.៧១៧** | ១០០,០០% | ៦៦.០៦៥.៦១០ | ១០០,០០% |

សម្រាប់ឆ្នាំ២០១៧ ក៏ដូចជា ឆ្នាំ២០១៦ ក.ស.ភ. មានកំណើនលើចំណូល ៣ប្រភេទធំៗ ដែលមានចំនួនជាង៩០% នៃចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្ម ។ ចំណូលទាំងនោះរួមមាន៖ ចំណូលលើកដាក់ក្រោមដងយោង ចំណូលលើកដាក់លើទីលាន និងចំណូលពីកិច្ចការផែ។

ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

ក.ស.ភ.សូមលើកយកប្រភេទចំណូលសំខាន់ៗចំនួន៤ ដើម្បីយកមកវិភាគដូចខាងក្រោម÷

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៧ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ចំណូលលើកដាក់ក្រោមដងយោង (Stevedoring) | ៧.៧៣៧.៤៦៩ | ៣១.២៩៨.០៦២ | ៦.៧១០.០៣៧ | ២៧.១៩៥.៧៨០ | ១.០២៧.៤៣២ | ១៥,៣១% | ៤.១០២.២៨២ | ១៥,០៨% |
| ចំណូលលើកដាក់លើទីលាន(LOLO) | ៦.៥៩៨.១០៩ | ២៦.៦៨៩.៣៥១ | ៥.៣៥៣.៩២៩ | ២១.៦៩៩.៨៧៤ | ១.២៤៤.១៨០ | ២៣,២៤% | ៤.៩៨៩.៤៧៧ | ២៣,០០% |
| ចំណូលពីកិច្ចការផែ | ៣.១៦៥.៦១៩ | ១២.៨០៤.៩២៩ | ២.៨៧៤.៣០០ | ១១.៦៤៩.៥៣៨ | ២៩១.៣១៩ | ១០,១៤% | ១.១៥៥.៣៩១ | ៩,៩២% |
| ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ | ៤២៦.០៧៣ | ១.៧២៣.៤៦៥ | ៤៧៨.៤៥៨ | ១.៩៣៩.១៩០ | (៥២.៣៨៥) | -១០,៩៥% | (២១៥.៧២៥) | -១១,១២% |

- ចំណូលលើកដាក់ក្រោមដងយោង (Stevedoring) : បានកើនឡើងចំនួន ៤.១០២.២៨២ ពាន់រៀល (១.០២៧.៤៣២ដុល្លារអាមេរិក) ឬស្មើនឹង ១៥,០៨% ពី២៧.១៩៥.៧៨០ពាន់រៀល (៦.៧១០.០៣៧ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ដល់ ៣១.២៩៨.០៦២ពាន់រៀល (៧.៧៣៧.៤៦៩ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ ការកើនឡើង ចំណូលនេះដោយសារតែកំណើនកុងតឺន័រឆ្លងកាត់ដែលមានចំនួន ៣៣.០២៤TEUs ឬស្មើនឹង ២១,៧៦% និងកំណើនទំនិញកយដែលមានចំនួន ៥៣.៨០៦តោន ឬស្មើនឹង ១២% សម្រាប់ឆ្នាំ២០១៧។ អត្រាកើនឡើងនៃចំណូលលើកដាក់ក្រោមដងយោង មានអត្រាទាបជាងកំណើនចំនួនកុងតឺន័រឆ្លងកាត់(TEUs) ដោយសារតែ ក.ស.ភ. ផ្តល់ជូននូវអត្រាតម្លៃពិសេសជូនក្រុមហ៊ុនដឹកជញ្ជូន នៅពេលដែលចំនួនកុងតឺន័រឆ្លងកាត់(TEUs) របស់ក្រុមហ៊ុននីមួយៗកើនទៅដល់កម្រិតមួយដែលបានកំណត់ទុកដោយ ក.ស.ភ.។

- ចំណូលលើកដាក់នៅទីលាន(LOLO): បានកើនឡើងចំនួន ៤.៩៨៩.៤៧៧ពាន់រៀល (១.២៤៤.១៨០ដុល្លារអាមេរិក) ឬស្មើនឹង ២៣% ពី ២១.៦៩៩.៨៧៤ពាន់រៀល (៥.៣៥៣.៩២៩ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ដល់ ២៦.៦៨៩.៣៥១ពាន់រៀល (៦.៥៩៨.១០៩ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ ការកើនឡើងចំណូលនេះបណ្តាលមកពីកំណើនកុងតឺន័រឆ្លងកាត់ដែលមានចំនួន ៣៣.០២៤TEUs ឬស្មើនឹង ២១,៧៦% បើធៀបនឹងឆ្នាំ២០១៦។ លើសពីនេះ ក.ស.ភ. បានផ្តល់នូវសេវាកម្មថ្មីមួយកាលពីដើមខែសីហា ឆ្នាំ២០១៦ គឺ *សេវាកម្មលើកដាក់ស្កេនកុងតឺន័រ* ដើម្បីត្រួតពិនិត្យទំនិញនៅទីលានកុងតឺន័រ។ សេវាកម្មថ្មីនេះ

ទទួលបានចំណូលសរុបចំនួន ៥០៥.៦០០ដុល្លារអាមេរិក ដែលបានបូកបញ្ចូលនៅក្នុងចំណូលលើកដាក់លើទីលាន សម្រាប់ឆ្នាំ២០១៧។

- ចំណូលពីកិច្ចការផែ (Port dues &charge): គឺអាស្រ័យលើចំនួននាវា និងចំណុះផ្ទុកនាវាដែលឆ្លងកាត់ ក.ស.ភ.។ ចំណូលពីកិច្ចការផែ បានកើនឡើងចំនួន ១.១៥៥.៣៩១ពាន់រៀល (២៩១.៣១៩ដុល្លារអាមេរិក) ឬស្មើនឹង៩,៩២% ពី ១១.៦៥៩.៥៣៨ (២.៨៧៥.៣០០ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ដល់ ១២.៨០៨.៩២៩ពាន់រៀល (៣.១៦៥.៦១៩ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ កត្តាចំបងនៃការកើនឡើងចំណូលនេះ គឺដោយសារតែការផ្លាស់ប្តូររបៀបនៃការគណនាចំណុះផ្ទុកនាវា (GRT) គឺក.ស.ភ. បានគណនាដោយផ្អែកទៅតាមចំណុះនាវា (GRT) ណាដែលមានចំនួនខ្ពស់ជាងគេរវាងវិញ្ញាបនបត្របញ្ជាក់ទម្ងន់អន្តរជាតិ និងវិញ្ញាបនបត្រចុះបញ្ជីរបស់នាវាដែលក្រុមហ៊ុនបានផ្ញើមក ក.ស.ភ. ។ ជាមួយគ្នានេះដែរ ក្នុងឆ្នាំ២០១៧ ចំនួននាវាឆ្លងកាត់មានការធ្លាក់ចុះចំនួន ០៣ជើង ឬស្មើនឹង ០,១៨% ដោយសារតែក្រុមហ៊ុនដឹកជញ្ជូនកុងតឺន័រខ្លះបានកាត់បន្ថយជើងនាវា ប៉ុន្តែចំណុះផ្ទុកនាវា(GRT) មានទំហំធំជាងមុន ដូចជាករណីក្រុមហ៊ុនដឹកជញ្ជូនកុងតឺន័រថ្មីមួយ ដែលមានចំណុះផ្ទុកនាវារហូតដល់ ១.៩២៥ ដែលមានចំនួន ៥០ជើង។

- ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រមានការថយចុះចំនួន ២១៥.៧២៥ ពាន់រៀល (៥២.៣៨៥ដុល្លារអាមេរិក) ឬស្មើនឹង១១,១២% ពី ១.៩៣៩.១៩០ ពាន់រៀល (៤៧៨.៤៥៨ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ ទៅ ១.៧២៣.៤៦៥ ពាន់រៀល (៤២៦.០៧៣ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ ជាមួយគ្នានេះដែរ គឺដោយសារមានការជួយសម្រួលដល់អតិថិជនលើការលើកដាក់ ដើម្បីយកកុងតឺន័រទៅស្តែន ដោយក.ស.ភ. គិតលើសេវាកម្មលើកដាក់ស្តែនកុងតឺន័រ។ បន្ទាប់មកយកកុងតឺន័រដែលស្តែនរួចទៅស្តុកទុកនៅទីតាំងផ្សេងពីទីលានស្តុកដែល ក.ស.ភ. គិតលើថ្លៃស្តុកឃ្លាំង។ ដូចនេះទើបបណ្តាលឲ្យ ចំណូលដែលបានមកពីស្តុកឃ្លាំងរបស់ ក.ស.ភ. មានការថយចុះ តែមានការកើនឡើងចំណូលលើកដាក់នៅទីលាន ដែលក្នុងនោះមានចំណូលលើសេវាកម្មលើកដាក់ស្តែនកុងតឺន័រ ។